**ការវាយតម្លៃដោយភាគីទី៣ ឆ្នាំ២០១៤**

**ក្រសួងការបរទេសនៃប្រទេសជប៉ុន**

# ការវាយតម្លៃលើជំនួយរៀបចំប្រព័ន្ធច្បាប់

ខែកុម្ភៈ ឆ្នាំ២ ០ ១ ៥

វិទ្យាស្ថានស្រាវជ្រាវទូទៅនៃក្រុមហ៊ុនមីស៊ប៊ីស៊ី

# អារម្ភកថា

របាយការណ៍នេះ ជាសមិទ្ធផលដែលវិទ្យាស្ថានស្រាវជ្រាវទូទៅនៃក្រុមហ៊ុនមីស៊ីប៊ីស៊ីសម្រេចបានក្នុងឱកាសនៃការអនុវត្តគម្រោងជំនួយដែលទទួលបានពីក្រសួងការបរទេសនៃប្រទេសជប៉ុនឆ្នាំ២០១៤ ដើម្បីវាយតម្លៃលើជំនួយរៀបចំប្រព័ន្ធច្បាប់។

បន្ទាប់ពីជំនួយអភិវឌ្ឍន៍របស់រដ្ឋាភិបាលជប៉ុន ហៅកាត់ថា ODA បានចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៥៤ រួចមក ក៏ចាប់ផ្តើមមានការផ្តល់ជំនួយក្នុងការដោះស្រាយបញ្ហាផ្សេងៗ ក្នុងសង្គមអន្តរជាតិ ស្របជាមួយនឹងការវិវត្តនៃសម័យកាល និង ការរីកលូតលាស់នៃប្រទេសកំពុងអភិវឌ្ឍន៍។ សព្វថ្ងៃនេះ ជំនួយ ODA កំពុងប្រឈមនឹងការចាំបាច់ត្រូវសម្រេចឲ្យបាននូវលទ្ធផលល្អ ប្រសិទ្ធិផល ហើយនិងប្រសិទ្ធិភាព និងគុណភាពខ្ពស់ជាងមុន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនៅក្នុងស្រុក និងលើឆាកអន្តរជាតិ។ ក្រសួងការបរទេសធ្វើការវាយតម្លៃលើការរៀបចំគោលនយោបាយODA ជារៀងរាល់ឆ្នាំ ហើយបានពឹងពាក់ស្ថាប័នខាងក្រៅឲ្យធ្វើការវាយតម្លៃនេះក្នុងនាមជាភាគីទី៣ ដើម្បីគោលដៅពីរគឺ ជានាឲ្យបាននូវការកែលំអរចំពោះការគ្រប់គ្រង ODA និងជានាទំនួលខុសត្រូវក្នុងការពន្យល់ទៅកាន់ប្រជាពលរដ្ឋជប៉ុន ឲ្យយល់ច្បាស់នូវការអនុវត្តគោលនយោបាយO D A ក្នុងគោលបំណងលើកស្ទួយតម្លាភាព និង សត្យានុភាពនៃការវាយតម្លៃ។

ការស្រាវជ្រាវវាយតម្លៃឆ្នាំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ពិនិត្យឡើងវិញនូវគោលនយោបាយទាំងមូលរបស់ប្រទេសជប៉ុនទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់ និង ផ្តល់អនុសាសន៍តាមរយៈមេរៀនដែលទទួលបានកន្លងមក ដើម្បីទុកជាការណែនាំ ចំពោះការរៀបចំ និងអនុវត្តឲ្យមានប្រសិទ្ធិផល និងគុណភាពនូវជំនួយរបស់រដ្ឋាភិបាលជប៉ុនក្នុងវិស័យច្បាប់នាពេលអនាគត។ គោលបំណងមួយទៀតគឺ ដើម្បីបំពេញទំនួលខុសត្រូវក្នុងការពន្យល់ទៅកាន់ប្រជាពលរដ្ឋជប៉ុន តាមរយៈការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលនៃការវាយតម្លៃលើការអនុវត្តជំនួយ ODA នេះ។

តាំងពីដំបូងរហូតដល់ទីបញ្ចប់នៃការវាយតម្លៃលើកនេះ យើងបានទទួលការដឹកនាំសកម្មភាពវាយតម្លៃទាំងមូលពីសំណាក់លោក សាតូ យ៉ាស៊ុណូបឺ ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យតូក្យូ (មហាវិទ្យាល័យសិល្បៈនិងវិទ្យាសាស្ត្រទូទៅ) ព្រមទាំងទទួលបានការផ្តល់ប្រឹក្សាទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់ប្រកបដោយជំនាញពីសំណាក់លោក គង់ ទេលី ជាសាស្ត្រាចារ្យរងនៅសាកលវិទ្យាល័យណាហ្គោយ៉ា (មជ្ឈមណ្ឌលផ្លាស់ប្តូរព័ត៌មានច្បាប់អាស៊ី)។ ទន្ទឹមនឹងនេះយើងក៏សូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងយុត្តិធម៌ ក្រសួងការបរទេស JICA ភាគីពាក់ព័ន្ធនឹង ODA ក្នុងប្រទេសទទួលជំនួយ ស្ថាប័នរដ្ឋាភិបាលនៅប្រទេសទទួលជំនួយម្ចាស់ជំនួយនានា អង្គការក្រៅរដ្ឋាភិបាល (NGO) ព្រមទាំងភាគីពាក់ព័ន្ធផ្សេងៗទៀតដែលបានផ្តល់កិច្ចសហប្រតិបត្តិការមកយើង ទាំងក្នុងពេលប្រមូលព័ត៌មានក្នុងប្រទេសជប៉ុននិងពេលចុះទៅសិក្សានៅប្រទេសទទួលជំនួយ។

ជាចុងបញ្ចប់ យើងសូមបញ្ជាក់ថា គំនិតដែលមាននៅក្នុងរបាយការណ៍នេះ គឺជាទស្សនៈរបស់ក្រុមការងារយើងផ្ទាល់ មិនឆ្លុះបញ្ចាំងពីទស្សនៈ ឬ គោលជំហររបស់រដ្ឋាភិបាលជប៉ុនឡើយ។

ខែកុម្ភៈ ឆ្នាំ ២០១៥

វិទ្យាស្ថានស្រាវជ្រាវទូទៅនៃក្រុមហ៊ុនមីស៊ូប៊ីស៊ី

សម្គាល់៖ របាយការណ៍វាយតម្លៃជាភាសាខ្មែរនេះ គឺជា របាយការណ៍សង្ខេបនៃការវាយតម្លៃជំនួយរៀបចំប្រព័ន្ធច្បាប់ដែលមានជាភាសាជប៉ុន។

# ការវាយតម្លៃលើជំនួយរៀបចំប្រព័ន្ធច្បាប់

## (សេចក្តីសង្ខេបនៃរបាយការណ៍)

**<u>អ្នកវាយតម្លៃ (ក្រុមការងារវាយតម្លៃ)</u>**

・អ្នកដឹកនាំ

លោក សាតូ យ៉ាស៊ីណូបឺ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ តូក្យូ មហាវិទ្យាល័យសិល្បៈនិងវិទ្យាសាស្ត្រទូទៅ

・អ្នកផ្តល់ប្រឹក្សា

លោក គង់ ទេលី សាស្ត្រាចារ្យរងនៃសាកលវិទ្យាល័យ ណាហ្គោយ៉ា មជ្ឈមណ្ឌលផ្លាស់ប្តូរព័ត៌មានច្បាប់អាស៊ី

・ក្រុមការងារផ្តល់ប្រឹក្សា

វិទ្យាស្ថានស្រាវជ្រាវទូទៅនៃក្រុមហ៊ុនមីស៊ីប៊ីស៊ី

**<u>រយៈពេលនៃការអនុវត្តគម្រោងវាយតម្លៃ</u>**

ពីខែសីហា ឆ្នាំ២០១៤ ដល់ ខែកុម្ភៈ ឆ្នាំ២០១៥

**<u>ប្រទេសដែលក្រុមការងារបានទៅធ្វើទស្សនកិច្ចសិក្សា</u>**

ប្រទេសវៀតណាម និងប្រទេសកម្ពុជា




សមិទ្ធផលជំនួយរៀបចំប្រព័ន្ធច្បាប់របស់ JICA នៅប្រទេសវៀតណាម

## <u>បរិបទជាសារវ័ន្ត គោលបំណង និង កម្មវត្ថុនៃការវាយតម្លៃ</u>

ដោយសារតែ មានតម្រូវការខ្ពស់នៃជំនួយរៀបចំប្រព័ន្ធច្បាប់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ប្រទេសជប៉ុនក៏បានអនុម័តនូវ «គោលការណ៍ជាមូលដ្ឋានទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់» (ដែលបានអនុម័តនាខែមេសា ឆ្នាំ២០០៩ និង ធ្វើវិសោធនកម្មនាខែឧសភា ឆ្នាំ២០១៣)។ ក្នុងបរិបទនេះ យើងបានធ្វើការវាយតម្លៃយ៉ាងទូលំទូលាយអំពីសមិទ្ធផលដែលទទួលបានពីការផ្តល់ជំនួយរៀបចំប្រព័ន្ធច្បាប់ ដើម្បីផ្តល់ជូនជាអនុសាសន៍កែលំអរជំនួយឲ្យទទួលបាននូវប្រសិទ្ធិផលប្រសើរជាងនេះទៅទៀតសម្រាប់ថ្ងៃអនាគត។ កម្មវត្ថុនៃគម្រោងវាយតម្លៃនេះ ផ្តោតទៅលើទិសដៅនៃជំនួយរៀបចំប្រព័ន្ធច្បាប់ដែលមានចែងក្នុងគោលនយោបាយរួមរបស់ ODA និង ក្នុងនយោបាយអនុវត្ត ODA សម្រាប់រយៈពេលកណ្តាល ហើយនិង «គោលការណ៍ជាមូលដ្ឋាននៃជំនួយរៀបចំប្រព័ន្ធច្បាប់» ដែលបានអនុម័ត នាខែមេសាឆ្នាំ២០០៩ និងធ្វើវិសោធនកម្ម នាខែឧសភាឆ្នាំ២០១៣។

## <u>ការបូកសរុបលទ្ធផលនៃការវាយតម្លៃ (សេចក្តីសង្ខេបរួម)</u>

ជារួម ការវាយតម្លៃទៅលើជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន ទាំងក្នុងទស្សនៈនៃវឌ្ឍនកម្ម និងទស្សនៈតាមផ្លូវការទូត សុទ្ធតែបានទទួលនូវលទ្ធផលវាយតម្លៃខ្ពស់។

## ●ការវាយតម្លៃក្នុងទស្សនៈនៃវឌ្ឍនកម្ម

(១) ភាពសមស្របនៃគោលនយោបាយ

ចំពោះភាពសមស្របនៃគោលនយោបាយ យើងធ្វើការវាយតម្លៃដោយឆ្លងកាត់តាមការវិភាគផ្អែកលើកត្តា៥យ៉ាង៖

«ភាពស៊ីសង្វាក់គ្នាជាមួយបញ្ហាអាទិភាពជាអន្តរជាតិ»

«ភាពស៊ីសង្វាក់គ្នាជាមួយគោលនយោបាយថ្នាក់លើនៃប្រទេសជប៉ុន»

«ភាពលេចធ្លោតាមការប្រៀបធៀបនៃជំនួយប្រទេសជប៉ុន»

«ការឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រទេសទទួលជំនួយ»

«ទំនាក់ទំនងនឹងគោលនយោបាយការទូតរបស់ប្រទេសជប៉ុន»

យើងបានវាយតម្លៃជារួមថា គោលនយោបាយសម្រាប់ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនពិតជាមានភាពសមស្របគ្រប់គ្រាន់។ ជាពិសេស យើងអាចវាយតម្លៃខ្ពស់បានចំពោះភាពលេចធ្លោតាមការប្រៀបធៀបនៃជំនួយរបស់ប្រទេសជប៉ុនក្នុងការរៀបចំប្រព័ន្ធច្បាប់។

(២) ប្រសិទ្ធផល

ជំនួយរៀបចំប្រព័ន្ធច្បាប់ ត្រូវធ្វើឡើងក្រោមសសរស្តម្ភចំនួនបួន គឺ ការរៀបចំវិធាន ការពង្រឹងមុខងាររបស់ស្ថាប័នអនុវត្តច្បាប់ ការពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ច្បាប់ និង ការបណ្តុះបណ្តាលធនធានមនុស្ស។ យើងអាចវាយតម្លៃបានថា តាមរយៈសសរស្តម្ភនីមួយៗ ប្រទេសជប៉ុនបានបន្សល់ទុកនូវមរតកជាវិជ្ជមានខ្លះៗដែលនាំទៅរកការពង្រឹងអភិបាលកិច្ចល្អ និង នីតិរដ្ឋនៅក្នុងប្រទេសទទួលជំនួយ។ ប៉ុន្តែ ទម្រាំតែអាចមើលឃើញនូវប្រសិទ្ធិផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់ វាត្រូវការពេលវេលាច្រើន ហើយយើងក៏បានលើកឡើងនូវចំណុចខ្លះៗផងដែរ ដូចជា សារសំខាន់នៃការពិនិត្យតាមដានស្ថានភាពក្នុងពេលអនាគត ហើយនិង បញ្ហាអំពើពុករលួយក្នុងស្ថាប័នយុត្តិធម៌ ដែលអាចជាបញ្ហារាំងដល់ការលើកស្ទួយប្រសិទ្ធិផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់ ជាដើម។

(៣ ) ភាពត្រឹមត្រូវនៃដំណើរការ

យើងអាចធ្វើការវាយតម្លៃខ្ពស់បានលើភាពត្រឹមត្រូវនៃដំណើរការ ដោយពិនិត្យទៅលើស្ថានភាពនៃការជំនុំពិភាក្សាជាមួយប្រទេសទទួលជំនួយ និង ការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ដែលមានកម្រិតជំនាញខ្ពស់ តាមរយៈការបញ្ជូនអ្នកជំនាញប្រកបដោយលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ដោយឡែកយើងក៏សង្កេតឃើញមានបញ្ហាមួយចំនួនដែលទាក់ទងជាចម្បងទៅនឹងកិច្ចសហការជាមួយម្ចាស់ជំនួយដទៃទៀត។

## ●ការវាយតម្លៃក្នុងទស្សនៈគោលនយោបាយការទូត

ជារួម យើងបានធ្វើការវាយតម្លៃខ្ពស់ដោយសន្និដ្ឋានថាជំនួយរៀបចំប្រព័ន្ធច្បាប់ពិតជាបានរួមវិភាគទានជាច្រើនទៅលើគោលនយោបាយការទូតរបស់ប្រទេសជប៉ុន។ លក្ខណៈពិសេសមួយនៃជំនួយវិស័យច្បាប់គឺការបង្កឲ្យមានបណ្តាញទាក់ទងគ្នាយ៉ាងរឹងមាំខាងធនធានមនុស្ស ហើយតាមរយៈនេះ អ្នកដែលយល់

ដឹង និងធ្លាប់ទាក់ទងស្និតស្នាលជាមួយប្រទេសជប៉ុនច្រើនក្លាយជាអ្នកមានតំណែង ឬ តួនាទីសំខាន់ៗក្នុងស្ថាប័នរដ្ឋបាលនានា និង ក្នុងសង្គមសេដ្ឋកិច្ច។

## **អនុសាសន៍**

**(១) ការបង្កើតឲ្យមានវេទិកាប្រឹក្សាអំពីគោលនយោបាយនៅថ្នាក់កំពូល**

យើងគិតថាគួរមានការបង្កើតនូវវេទិកាថ្នាក់កំពូលក្នុងជួររដ្ឋាភិបាលជប៉ុនដើម្បីរៀបចំគោលនយោបាយយ៉ាងសកម្ម និង ត្រួតពិនិត្យជំនួយរៀបចំប្រព័ន្ធច្បាប់ឲ្យបានញឹកញាប់ជាងការធ្វើវិសោធនកម្មលើ "គោលការណ៍ជាមូលដ្ឋានទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់"នោះ។

**(២) ការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ចំពោះស្ថាប័នដែលមានសិទ្ធិសម្រេចពីគោលនយោបាយ**

បន្ថែមលើការអនុវត្តជំនួយនៅថ្នាក់មូលដ្ឋាន យើងក៏ត្រូវការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់នៅថ្នាក់ស្ថាប័នដែលមានសិទ្ធិសម្រេចពីគោលនយោបាយផងដែរ។

**(៣)ការអនុវត្តជំនួយតាមដានស្ថានភាពនៃការអនុវត្តច្បាប់**

ចំពោះការអនុវត្តជំនួយជាបន្តទៅអនាគត ការបន្ថែមនូវប្រភេទជំនួយទាក់ទងនឹងការប្រមូលព័ត៌មានសម្រាប់រួមចំណែកដល់កិច្ចការតាមដានស្ថានភាពនៃការអនុវត្តច្បាប់ក៏មានសារៈប្រយោជន៍ណាស់ដែរ។

**(៤) ការពង្រឹងសកម្មភាពផ្សព្វផ្សាយដើម្បីជម្រុញ និងសម្រួលដល់ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌និងច្បាប់**

ការផ្សព្វផ្សាយស្តីពីសកម្មភាពជំនួយប្រព័ន្ធច្បាប់តាមប្រព័ន្ធផ្សព្វផ្សាយនានានៅក្នុងប្រទេសទទួលជំនួយទៅកាន់ប្រជាពលរដ្ឋទូទៅឲ្យបានយល់ដឹងអំពីច្បាប់ និងប្រព័ន្ធយុត្តិធម៌គឺជាកិច្ចការសំខាន់មិនអាចខ្វះបាន។

**(៥) ការពង្រឹងនូវទំនាក់ទំនងជាមួយម្ចាស់ជំនួយផ្សេងទៀតនិងអង្គការអន្តរជាតិនានា**

យើងយល់ឃើញថា ដោយប្រើប្រាស់នូវភាពលេចធ្លោតាមការប្រៀបធៀបនៃជំនួយរបស់ប្រទេសជប៉ុន ជាមគ្គុទេសន៍ណែនាំសម្រាប់ជំនួយរៀបចំប្រព័ន្ធច្បាប់ដែលធ្វើឡើងដោយម្ចាស់ជំនួយទាំងអស់ឲ្យបានយ៉ាងសកម្ម យើងក៏អាចលើកស្ទួយបានមួយកម្រិតថែមទៀតនូវសារៈសំខាន់នៃវត្តមានជំនួយជប៉ុនក្នុងការរៀបចំប្រព័ន្ធច្បាប់ផងដែរ។

**(៦) ការអនុវត្តជំនួយដោយសហការជាមួយស្ថាប័នឯកជនក្នុងដំណាក់កាលជួយបម្រុងការអនុវត្តច្បាប់**

វាជាការសំខាន់ត្រូវរៀបចំឲ្យមានប្រព័ន្ធការងារមួយ ដែលអាចសម្រួលដល់ការបញ្ជូនមេធាវីទៅបំពេញការងារយ៉ាងសកម្មនៅប្រទេសក្រៅ ហើយនិង ផ្តល់ជូនពួកគាត់នូវកិច្ចឧបត្ថមគាំទ្រក្នុងកំឡុងពេលនៃបេសកម្មនោះ ដោយចាត់ទុក JICA ជាភ្នាក់ងារទទួលខុសត្រូវចម្បងក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់ និងព្យាយាមពង្រឹងបន្ថែមឲ្យបានកាន់តែខ្លាំងជាងមុននូវកិច្ចសហការជាមួយសម្ព័ន្ធគណៈមេធាវីជប៉ុន ឬស្ថាប័នឯកជនដទៃទៀត។

**(៧) ការផ្សព្វផ្សាយយ៉ាងសកម្មជាសាធារណៈនូវឯកសារដែលបានទទួលពីជំនួយរៀបចំប្រព័ន្ធច្បាប់**

ចំពោះឯកសារទាំងឡាយដែលបានចងក្រងឡើងដោយជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន និងដែលទទួលបានការវាយតម្លៃខ្ពស់ពីសំណាក់អ្នកច្បាប់ ព្រមទាំងអ្នកចូលរួមសិក្ខាសាលានៅប្រទេសទទួលជំនួយ យើងគិតថាគួរធ្វើការផ្សព្វផ្សាយយ៉ាងសកម្មនូវឯកសារទាំងនោះ ជាសាធារណៈតាមរូបភាពមួយដែលសម្រួលដល់ការទទួលបានដោយងាយស្រួល។ ការផ្សព្វផ្សាយឯកសារទាំងនេះ អាចនឹងបង្កើនប្រសិទ្ធិផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុនបាន។

ដោយហេតុថា ភាគីពាក់ព័ន្ធនឹងជំនួយរៀបចំប្រព័ន្ធច្បាប់ មិនមែនមានតែក្រសួងការបរទេស និង JICA ប៉ុណ្ណោះទេ នៅមាន ក្រសួងយុត្តិធម៌ ក្រសួងឧស្សាហកម្មនិងសេដ្ឋកិច្ច ក្រសួងហិរញ្ញវត្ថុ ក្រសួងអប់រំ និង ក្រសួងឬនាយកដ្ឋានដទៃទៀត ព្រមទាំងមានចំណែកនៃអង្គការឧស្សាហកម្ម សាកលវិទ្យាល័យ គណៈមេធាវី និង NGO ទៀតផង។ ក្នុងរបាយការណ៍វាយតម្លៃលើកនេះ ក្រៅអំពីអនុសាសន៍ដែលធ្វើឡើងសម្រាប់ជូនទៅក្រសួងការបរទេស និងJICA យើងក៏បានជូនចំពោះភាគីទាំងអស់ដែលពាក់ព័ន្ធនឹងជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន នូវអនុសាសន៍មួយចំនួនក្រោមចំណងជើងថា “ការពង្រីកប្រព័ន្ធជំនួយដោយចាប់អារម្មណ៍លើការផ្តល់ផលប្រយោជន៍ដល់សហគ្រាសជប៉ុន” និង “ការបណ្តុះបណ្តាលអ្នកជំនាញការក្នុងវិស័យជំនួយច្បាប់” ផងដែរ។



កិច្ចប្រជុំជាមួយក្រសួងយុត្តិធម៌នៃប្រទេសវៀតណាម (ឆ្វេង) និង



សកម្មភាពពិភាក្សាក្រុមនៅប្រទេសកម្ពុជា (កិច្ចសហប្រតិបត្តិការបច្ចេកទេសដោយ JICA)(ស្តាំ)

# មាតិកា


**ជំពូកទី១ ទិសដៅសម្រាប់អនុវត្តការវាយតម្លៃ** ........ 8

**១.១. បរិបទជាសារវតា និង នៃការវាយតម្លៃ** ........ 8

**១.២. កម្មវត្ថុនៃការវាយតម្លៃ** ........ 9

**១.៣. វិធីសាស្ត្រអនុវត្ត និង ក្របខ័ណ្ឌនៃការវាយតម្លៃ** ........ 12

១.៣.១. វិធីសាស្ត្រអនុវត្តការវាយតម្លៃ ........ 12

១.៣.២. ក្របខ័ណ្ឌនៃការវាយតម្លៃ ........ 12

**ជំពូកទី២ សេចក្ដីសង្ខេបនៃការវាយតម្លៃ និង អនុសាសន៍** ........ 13

**២.១. សេចក្ដីសង្ខេបនៃការវាយតម្លៃ** ........ 13

២.១.១. ភាពសមស្របនៃគោលនយោបាយ ........ 13

២.១.២. ប្រសិទ្ធិផល ........ 13

២.១.៣. ភាពត្រឹមត្រូវនៃដំណើរការ ........ 16

២.១.៤. ការវាយតម្លៃក្នុងទស្សនៈគោលនយោបាយការទូត ........ 18

**២.២. អនុសាសន៍ផ្អែកលើការវាយតម្លៃ** ........ 18

២.២.១. អនុសាសន៍ ........ 18

**២.៣. អនុសាសន៍ជារួមចំពោះភាគីពាក់ព័ន្ធទាំងអស់ក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់ជប៉ុន** ........ 27

## ជំពូកទី១ ទិសដៅសម្រាប់អនុវត្តការវាយតម្លៃ

១.១. បរិបទជាសារវតា និង នៃការវាយតម្លៃ

ជំនួយអភិវឌ្ឍន៍របស់រដ្ឋាភិបាល (ODA) គឺជាសសរមួយយ៉ាងសំខាន់ក្នុងការធ្វើវិភាគទានរបស់ប្រទេសជប៉ុនទៅកាន់សង្គមអន្តរជាតិ។ ជាងនេះទៅទៀត តាមរយៈការវាយតម្លៃទៅលើជំនួយ ODA នេះ ក្រសួងការបរទេសកំពុងប្រឹងប្រែងជម្រុញឲ្យការអនុវត្តជំនួយអាចទទួលបាននូវលទ្ធផល និង ប្រសិទ្ធិភាពល្អប្រសើរ ហើយនិងគុណភាពកាន់តែខ្ពស់។ ជំនួយរៀបចំប្រព័ន្ធច្បាប់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ សំដៅជួយឲ្យប្រទេសទាំងនោះអាចមានលទ្ធភាពប្រឹងប្រែងជួយខ្លួនឯងតាមរយៈអភិបាលកិច្ចល្អ ព្រមទាំងជាជំនួយសម្រាប់រៀបចំឡើងនូវមូលដ្ឋានគ្រឹះដែលមិនអាចខកខានបាន ដើម្បីឲ្យប្រទេសកំពុងអភិវឌ្ឍអាចបន្តការអភិវឌ្ឍដោយចេរភាព។ ដូច្នេះ ជំនួយប្រភេទនេះក៏ត្រូវបានកំណត់ទុកថាជាប្រការចម្បងមួយក្នុងទិសដៅនយោបាយសំខាន់ៗទាក់ទងនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ក្រសួងការបរទេសជប៉ុនផងដែរតាំងពីមុនមក។

នៅក្នុង «គោលការណ៍ជាមូលដ្ឋាននៃជំនួយរៀបចំប្រព័ន្ធច្បាប់[កែសម្រួលឡើងវិញ]» ដែលបានរៀបចំឡើង នាឆ្នាំ២០១៣ បានបញ្ជាក់ជាថ្មីឡើងវិញនូវគំនិតមូលដ្ឋានទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន ហើយនិង កំណត់ថានឹងផ្តល់ជំនួយនេះចំពោះប្រទេសចំនួន៨ រួមមាន ប្រទេសឥណ្ឌូនេស៊ី ប្រទេសវៀតណាម ប្រទេសមីយ៉ាន់ម៉ា ប្រទេសម៉ុងហ្គោលី ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសអូស្បេគីស្ថាន និង ប្រទេសបង់ក្លាដេស ប៉ុន្តែប្រទេសជប៉ុនគួរមានត្រៀមលក្ខណៈនឹងឆ្លើយតបចំពោះភាពចាំបាច់ ហើយនិងសេចក្តីត្រូវការជាក់ស្តែងនៃប្រទេសជាដៃគូបន្ថែមទៀត នាពេលអនាគតដែរ ដោយរាប់បញ្ចូលទាំងប្រទេសដទៃទៀត ក្នុងតំបន់អាស៊ី និង បណ្តាប្រទេសនៅទ្វីបអាហ្វ្រិកទៀតផង។

ជំនួយរៀបចំប្រព័ន្ធច្បាប់ ដែលបានអនុវត្តតាំងពីដើមមក គឺរួមមាន ការពង្រឹងមុខងាររបស់ស្ថាប័នអនុវត្តច្បាប់ (តុលាការ ជាអាទិ៍) និងការតាក់តែងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋានដូចជាច្បាប់រដ្ឋប្បវេណី ជាដើម។ ប៉ុន្តែបន្ថែមពីលើនេះក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីជួយរៀបចំបរិយាកាសល្អសម្រួលដល់ដំណើរការនៃធុរកិច្ចជំនួយរៀបចំប្រព័ន្ធច្បាប់ ក៏បានចាប់ផ្តើមពង្រីកវិសាលភាពរបស់ខ្លួន ដោយរួមបញ្ចូលនូវជំនួយរៀបចំខាងវិស័យពន្ធដារសំដៅធ្វើឲ្យការងារពាណិជ្ជកម្មអាចដំណើរការបានរលូន និងរៀបចំប្រព័ន្ធ ឬ ស្ថាប័នវាយតម្លៃបញ្ជាក់អំពីបមាណើយ និង បទដ្ឋាននានា។។

ផ្អែកតាមស្ថានភាពដូចបានរៀបរាប់ខាងលើ យើងបានធ្វើការវាយតម្លៃជារួមចំពោះសមិទ្ធផល ដែលទទួលបានក្រោមជំនួយរៀបចំប្រព័ន្ធច្បាប់កន្លងមកនិងធ្វើការផ្តល់អនុសាសន៍ដើម្បីឲ្យការអនុវត្តជំនួយអាចប្រព្រឹត្តទៅបានប្រកបដោយផ្លែផ្កា ក្នុងបរិបទនៃគោលការណ៍ជា

មូលដ្ឋានថ្មី។ ជាងនេះទៅទៀត យើងក៏បានរៀបចំគម្រោងផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃនេះជាសាធារណៈ ដើម្បីបំពេញនូវគណនីភាព ចំពោះប្រជាពលរដ្ឋ ហើយថែមទាំងបានស្វែងរកយោបល់តបពីសំណាក់ស្ថាប័នម្ចាស់ជំនួយនានា ចំពោះលទ្ធផលនៃការវាយតម្លៃនេះ។

## ១.២. កម្មវត្ថុនៃការវាយតម្លៃ

ការវាយតម្លៃនេះ ត្រូវបានអនុវត្តឡើងដោយផ្តោតលើកម្មវត្ថុគោលនយោបាយ ODA ទាក់ទងនឹងជំនួយសម្រាប់រៀបចំប្រព័ន្ធច្បាប់ ដែលជារបៀបវីរៈចម្បងមួយក្នុងជំនួយរបស់ប្រទេសជប៉ុន។

ចំពោះ និយមន័យនៃពាក្យថា ជំនួយរៀបចំប្រព័ន្ធច្បាប់ ដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍វាយតម្លៃនេះ យើងបានយោងតាមនិយមន័យមានចង្អុលបង្ហាញនៅក្នុង «របាយការណ៍ស្រាវជ្រាវស្តីពីអភិបាលកិច្ចល្អ» ដែលបានចងក្រងឡើងដោយ JICA ដូចតទៅ «ជំនួយរៀបចំប្រព័ន្ធច្បាប់ គឺជាជំនួយទាំងឡាយ ដែលជួយដល់កិច្ចប្រឹងប្រែងរៀបចំច្បាប់នៅប្រទេសកំពុងអភិវឌ្ឍន៍ មិនមែនត្រឹមតែការតាក់តែងច្បាប់ ឬការជម្រុញនីតិបញ្ញាត្តប្បនីយកម្មតែប៉ុណ្ណោះទេ ថែមទាំងមានការរៀបចំប្រព័ន្ធនានាសម្រាប់ការប្រតិបត្តិ និង ការអនុវត្តច្បាប់(ជំនួយសម្រាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌) ដោយរួមមានទាំងជំនួយទាក់ទងនឹងការបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់អនុវត្តច្បាប់ទាំងនោះផងដែរ»[1]។ ឧទាហរណ៍ជាក់ស្តែងនៃសកម្មភាពជំនួយនេះសំខាន់គឺមាន ការរៀបចំលិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋានខាងរដ្ឋប្បវេណី និង ខាងវិស័យសេដ្ឋកិច្ច កំណែទម្រង់ក្នុងការអនុវត្តវិស័យយុត្តិធម៌ និង ការបណ្តុះបណ្តាលអ្នកច្បាប់។ យើងក៏ទទួលបានតាមរយៈកិច្ចសំភាសន៍ជាមួយភាគីពាក់ព័ន្ធនូវព័ត៌មានថា មានជំនួយផ្នែកនគបាល និងសកម្មភាពរក្សាសណ្តាប់ធ្នាប់ ជំនួយផ្នែកពន្ធដាពន្ធគយផងដែរ ប៉ុន្តែដោយសារការអនុវត្តជំនួយទាំងនោះមានទ្រង់ទ្រាយ និងទស្សនៈទានខុសពីនិយមន័យខាងលើ ដូច្នេះយើងសូមទុកជំនួយខាងផ្នែកទាំងនេះឲ្យនៅក្រៅកម្មវត្ថុនៃការវាយតម្លៃលើកនេះ។

ដូចដែលបានលើកឡើងខាងលើ «គោលដៅជាមូលដ្ឋាននៃជំនួយរៀបចំប្រព័ន្ធច្បាប់» ដែលបានអនុម័ត នាខែមេសា ឆ្នាំ២០០៩ និងធ្វើវិសោធនកម្មនាខែឧសភាឆ្នាំ២០១៣ គឺជាលិខិតបទដ្ឋានគោលនយោបាយស្តីពីជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុនដែលមានរៀបរាប់យ៉ាងលម្អិតអំពីគោលការណ៍ជាមូលដ្ឋានសម្រាប់ការផ្តល់ជំនួយ។ ក្រៅពីនេះ«គោលនយោបាយរួមរបស់ ODA» និង «គោលនយោបាយ ODA រយៈពេលកណ្តាល» ព្រមទាំង ទិសដៅ និងគម្រោងផែនការជំនួយនៅតាមប្រទេសនីមួយៗ ក៏មានបញ្ជាក់ពីគោលនយោបាយស្តីពីជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនផងដែរ។ មិនតែប៉ុណ្ណោះ JICA ដែលជាស្ថាប័នអនុវត្ត

[1] JICA «របាយការណ៍ស្រាវជ្រាវស្តីពីជំនួយអភិបាលល្អ JICA៖ ការបង្កើតប្រព័ន្ធប្រជាធិបតេយ្យ ការពង្រឹងមុខងាររដ្ឋបាល ជំនួយរៀបចំប្រព័ន្ធច្បាប់ » ឆ្នាំ២០០៤។

ជំនួយក៏បានចង្អុលបង្ហាញពី គោលនយោបាយស្តីពីជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនដែរ។ ដោយពិចារណាលើចំណុចទាំងអស់ខាងលើ យើងបានកំណត់កម្មវត្ថុនៃការវាយតម្លៃដោយសំអាងលើ គោលការណ៍ទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់ដែលមានរៀបរាប់នៅក្នុងគោលនយោបាយរួមរបស់ ODA និង គោលនយោបាយ ODA សម្រាប់រយៈពេលកណ្តាល ព្រមទាំង «គោលការណ៍ជាមូលដ្ឋាននៃជំនួយរៀបចំប្រព័ន្ធច្បាប់» ដែលបានអនុម័ត នាខែមេសាឆ្នាំ២០០៩ និង ធ្វើវិសោធនកម្មនាខែឧសភាឆ្នាំ២០១៣។ ប៉ុន្តែ ចំពោះចំណុចណាដែលមិនបានរៀបរាប់លម្អិតជាក់លាក់នៅក្នុងលិខិតបទដ្ឋានទាំងនេះ យើងបានផ្អែកតាមឯកសារពាក់ព័ន្ធបន្ថែមទៀត ដើម្បីរៀបចំគំនូសតារាងលំហូរកំណត់គោលដៅចុងក្រោយសម្រាប់ធ្វើការវាយតម្លៃ។

ចំពោះកំឡុងពេលដែលត្រូវពិនិត្យក្នុងកម្មវត្ថុនៃការវាយតម្លៃនេះ យើងបានរាប់បញ្ចូលនូវជំនួយរៀបចំប្រព័ន្ធច្បាប់ទាំងឡាយ ដែលជប៉ុនបានចាប់ផ្តើមឡើងជាដុំកំភួនក្រោយនាឆ្នាំ១៩៩៦។ ប៉ុន្តែ យើងក៏បានយកចិត្តទុកដាក់លើការកែសម្រួលគោលនយោបាយរួមរបស់ ODA នាឆ្នាំ២ ០ ០ ៣ ដែលជាគោលនយោបាយថ្នាក់ខ្ពស់បំផុតដឹកនាំមាគ៌ាជំនួយរបស់ជប៉ុននៅក្រៅប្រទេស។ ម្យ៉ាងទៀត ដោយយល់ឃើញថានេះជាលើកដំបូងដែលក្រសួងការបរទេសបានអញ្ជើញភាគីទី៣ មកធ្វើការវាយតម្លៃលើជំនួយរៀបចំប្រព័ន្ធច្បាប់នោះ យើងក៏បានដាក់បញ្ចូលក្នុងកម្មវត្ថុនៃការវាយតម្លៃនូវជំនួយខ្លះដែលបានចាប់អនុវត្តតាំងពីមុនឆ្នាំ១៩៩៦ មកផងដែរតាមសេចក្តីចាំបាច់។




**រូបភាពទី ១-១ គំនូសតាងលំហូរកំណត់គោលដៅចម្បងដែលរៀបរាប់ក្នុងការវាយតម្លៃនេះ**

អាគតដ្ឋាន៖ គូសដោយក្រុមវាយតម្លៃដោយផ្អែកលើ "គោលដៅជាមូលដ្ឋាននៃជំនួយរៀបចំប្រព័ន្ធច្បាប់" (ខែឧសភា ឆ្នាំ២០១៣)ជាអាទិ៍។

## ១.៣. វិធីសាស្ត្រអនុវត្ត និង ក្របខ័ណ្ឌនៃការវាយតម្លៃ

### ១.៣.១. វិធីសាស្ត្រអនុវត្តការវាយតម្លៃ

កម្មវត្ថុនៃការវាយតម្លៃនេះ ផ្ដោតលើគោលនយោបាយ ODA ទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់ដែលជារបៀបវរៈបង្គោលមួយនៅក្នុងជំនួយរៀបចំរបស់ប្រទេសជប៉ុន។ យើងធ្វើការវាយតម្លៃជារួម ដោយផ្អែកលើទស្សនៈទានពីរយ៉ាង គឺ ទស្សនៈនៃវិឌ្ឍនកម្មចំណុចបីចំណុចរួមមាន «ភាពសមស្របនៃគោលនយោបាយ» «ប្រសិទ្ធិផល» «ភាពត្រឹមត្រូវនៃដំណើរការ» និងទស្សនៈទានក្នុង «វិស័យការទូត»។ យើងអនុវត្តការវាយតម្លៃនេះដោយអនុលោមតាម «សេចក្ដីណែនាំចំពោះការវាយតម្លៃ ODA បោះពុម្ពលើកទី៨» និងធ្វើសេចក្ដីយោងទៅតាមប្រការទាំង៥ចំណុច សម្រាប់ការវាយតម្លៃដែលអនុម័តដោយអង្គការ OECD-DAC។

### ១.៣.២. ក្របខ័ណ្ឌនៃការវាយតម្លៃ

ដើម្បីធ្វើការវាយតម្លៃលើកនេះ យើងបានរៀបចំឡើងនូវក្របខ័ណ្ឌរួមសម្រាប់ការវាយតម្លៃ ដោយរួមបញ្ចូល «ទស្សនៈទានដែលប្រើប្រាស់សម្រាប់ការវាយតម្លៃ» «ប្រការនានាជាប្រធានបទនៃការវាយតម្លៃ» និង «សូចនាករសម្រាប់ការវាយតម្លៃ»។

## ជំពូកទី២ សេចក្តីសង្ខេបនៃការវាយតម្លៃ និង អនុសាសន៍

### ២.១. សេចក្តីសង្ខេបនៃការវាយតម្លៃ

### ២.១.១. ភាពសមស្របនៃគោលនយោបាយ

ចំពោះភាពសមស្របនៃគោលនយោបាយ យើងធ្វើការវាយតម្លៃដោយឆ្លងកាត់តាមការវិភាគផ្អែកលើកត្តា៥យ៉ាង៖
«ភាពស៊ីសង្វាក់គ្នាជាមួយបញ្ហាអាទិភាពជាអន្តរជាតិ»
«ភាពស៊ីសង្វាក់គ្នាជាមួយគោលនយោបាយថ្នាក់លើនៃប្រទេសជប៉ុន»
«ភាពលេចធ្លោតាមការប្រៀបធៀបនៃជំនួយប្រទេសជប៉ុន»
«ការឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រទេសទទួលជំនួយ»
«ទំនាក់ទំនងនឹងគោលនយោបាយការទូតរបស់ប្រទេសជប៉ុន»

យើងបានវាយតម្លៃជារួមថាគោលនយោបាយសម្រាប់ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនពិតជាមានភាពសមស្របគ្រប់គ្រាន់។ ជាពិសេស ប្រទេសទទួលជំនួយក៏បានធ្វើការវាយតម្លៃខ្ពស់ទាក់ទងនឹងភាពលេចធ្លោនៃជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន បើធៀបនឹងប្រទេសម្ចាស់ជំនួយផ្សេងៗទៀត តាមរយៈកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសដែលមានការបញ្ជូនអ្នកជំនាញរយៈពេលវែងមកបំពេញការងារនៅប្រទេសទទួលជំនួយដោយផ្ទាល់។ ពាក់ព័ន្ធនឹងគោលនយោបាយស្តីពីជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន យើងសង្កេតឃើញថា មានភាពស៊ីសង្វាក់គ្នាយ៉ាងល្អជាមួយគោលនយោបាយការបរទេសគោលនយោបាយ ODAសម្រាប់រយៈពេលកណ្តាល និងគោលនយោបាយរួមរបស់ ODA ជប៉ុន។ ម្យ៉ាងទៀត យើងក៏អាចវាយតម្លៃសន្និតបានថា វាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងនិន្នាការនៃជំនួយអន្តរជាតិដែលមានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) និង កែលំអរអភិបាលកិច្ចផងដែរ ។ យើងថែមទាំងអាចធ្វើការវាយតម្លៃបានថា ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនត្រូវបានរៀបចំឡើងក្នុងគម្រោងផែនការសមស្រប ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រទេសទទួលជំនួយដែលបានចែងទុកយ៉ាងច្បាស់ ក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួនស្តីពីភាពចាំបាច់ក្នុងការរៀបចំប្រព័ន្ធច្បាប់ដើម្បីសកម្មភាពសេដ្ឋកិច្ច ការរៀបចំប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ និង កំណែទម្រង់វិស័យយុត្តិធម៌ជាអាទិ៍។

### ២.១.២. ប្រសិទ្ធិផល

ជំនួយរៀបចំប្រព័ន្ធច្បាប់បានប្រព្រឹត្តឡើងក្រោមសសរស្តម្ភបួនគឺការរៀបចំវិធាននានា ការពង្រឹងមុខងាររបស់ស្ថាប័នអនុវត្តច្បាប់ ការពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ច្បាប់ និងការ

បណ្តុះបណ្តាលធនធានមនុស្ស។ រហូតមកដល់ពេលនេះ យើងអាចសន្និដ្ឋានបានថា តាមរយៈសសរស្តម្ភទាំងបួន គម្រោងជំនួយរបស់ប្រទេសជប៉ុនបានបន្សល់ទុកនូវមរតកជាវិជ្ជមានខ្លះៗនាំទៅរកការពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋនៅក្នុងប្រទេសទទួលជំនួយ។ ជាពិសេសចំពោះជំនួយលើការរៀបចំវិធាន និងការបណ្តុះបណ្តាលធនធានមនុស្ស យើងអាចមើលឃើញលទ្ធផលនៃជំនួយបានយ៉ាងងាយដោយចាត់ទុកថា ការប្រកាសឲ្យប្រើច្បាប់នានា និងចំនួនសិស្សបញ្ចប់ការសិក្សា ព្រមទាំងការសម្តែងសមត្ថភាពរបស់ពួកគេ គឺជាកត្តាសំខាន់សម្រាប់វាយតម្លៃអំពីលទ្ធផលដែលសម្រេចបានពីជំនួយ។ ចំណែកឯ សសរស្តម្ភពីរទៀត យើងក៏អាចធ្វើការវាយតម្លៃបានខ្លះៗ តាមរយៈការពិនិត្យមើលការរៀបចំសិក្ខាសាលានានាផងដែរ។

ដោយឡែក ចំពោះសមិទ្ធផលសរុបដែលទទួលបានពីការប្រមូលផ្តុំលទ្ធផលនៃសកម្មភាពនីមួយៗវិញ យើងពិបាកនឹងទទួលបាននូវសំអាងជាក់លាក់ដែលមានលក្ខណៈសត្យានុម័តដើម្បីធ្វើការវាយតម្លៃអំពីឥទ្ធិពលនៃសមិទ្ធផលសរុបនោះ។ ក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់ទាំងនេះ បន្ទាប់ពីចាប់ផ្តើមអនុវត្តជំនួយរួចហើយយើងត្រូវការពេលវេលាច្រើនដើម្បីអនុញ្ញាតឲ្យសមិទ្ធផលទាំងអស់អាចកើតឡើងបានប្រកបដោយប្រសិទ្ធិភាព នៅក្នុងវិស័យយុត្តិធម៌ និងរដ្ឋបាល។

ចំពោះជំនួយក្នុងការរៀបចំវិធាននានា ដូចជា ជំនួយទាក់ទងនឹងវិស័យច្បាប់ សេដ្ឋកិច្ចជាដើម ដែលជាច្បាប់ពិសេសមានវិសាលភាពអនុវត្តចង្អៀត ហើយមានការពាក់ព័ន្ធយ៉ាងជិតស្និតជាមួយនឹងការអនុវត្តជាក់ស្តែងនោះ យើងអាចមើលឃើញនូវសមិទ្ធផលបានពីយ៉ាងងាយស្រួលជាងគេ តាមរយៈការកែលំអរប្រសិទ្ធិភាពនៃការអនុវត្តជំនួយ។ ផ្ទុយទៅវិញចំពោះជំនួយទាក់ទងនឹងច្បាប់គ្រឹះដូចជា ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណីវិញ ដែលភាគច្រើនមានគោលបំណងក្នុងការកែទម្រង់មូលដ្ឋានគ្រឹះនៃច្បាប់នោះ ចាំបាច់ត្រូវការពេលវេលាច្រើនសម្រាប់ធ្វើបំលាស់ប្តូរការអនុវត្តប្រព័ន្ធយុត្តិធម៌ ឲ្យបានស្របជាមួយនឹងការប្រែប្រួលនូវគោលគំនិតជាសារវ័ននៃប្រព័ន្ធច្បាប់និងដើម្បីអាចផ្លាស់ប្តូរការយល់ដឹងរបស់មនុស្សម្នា ព្រមទាំងមានការផ្លាស់ប្តូរក្នុងសង្គមបានថែមទៀត។ ប៉ុន្តែ តម្រូវការនៃពេលវេលានេះ ក៏បង្ហាញឲ្យឃើញថាវាជាកិច្ចការមួយដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ និង មានឥទ្ធិពលខ្លាំងដែរ។

បន្ទាប់មកទៀត ចំពោះការពង្រឹងមុខងាររបស់ស្ថាប័នអនុវត្តច្បាប់វិញ ចាំបាច់ត្រូវមានដំណាក់កាលនៃការរៀបចំវិធានជាមុនសិន ហើយបន្ទាប់មកត្រូវរង់ចាំនូវដំណាក់កាលដែលលទ្ធផលទាំងនោះលេចរូបរាងឡើងជាបណ្តើរៗ។ ជាទូទៅ ដើម្បីអនុវត្តច្បាប់ដែលបានតាក់តែងឡើងឲ្យត្រឹមត្រូវ លុះត្រាតែស្ថាប័នពាក់ព័ន្ធទាំងឡាយមានការយល់ដឹងអំពីច្បាប់ទាំងនោះឲ្យបានត្រឹមត្រូវ និងត្រូវមានភាពស៊ីសង្វាក់គ្នារវាងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់នោះផង។ ទាក់ទងនឹងចំណុចនេះ ជំនួយនៃប្រទេសជប៉ុនត្រូវបង្កើននូវភាពច្នៃប្រឌិតរបស់ខ្លួនឲ្យបានប្រសើរជាងនេះថែមទៀត។ ជាគោលការណ៍ ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនតម្រូវឲ្យមានការពិភាក្សាជាមួយស្ថាប័នជាដៃគូដែលបានជ្រើសតាំងរួចស្រេចហើយ

នោះឲ្យបានច្បាស់លាស់ជាមុនសិន។ យើងទទួលស្គាល់ថា នឹងមានភាពរីកចម្រើនចំពោះការអនុវត្តនៅក្នុងវិស័យយុត្តិធម៌ ក្នុងឱកាសដែលយើងមានស្ថាប័នចៅក្រម ឬ ស្ថាប័នអយ្យការធ្វើជាស្ថាប័នដៃគូផ្ទាល់។ ដោយឡែក នៅក្នុងការអនុវត្តច្បាប់ ក្រៅពីស្ថាប័នជាដៃគូផ្ទាល់ យើងនៅមានស្ថាប័នជាច្រើនផ្សេងទៀតដែលពាក់ព័ន្ធ។ ប្រសិនបើគ្មានការប្រាស្រ័យទាក់ទងជាមួយស្ថាប័នទាំងអស់នោះទេ ការកែលំអរការអនុវត្តច្បាប់ពិតជាមិនអាចប្រព្រឹត្តទៅបានដោយរលូននោះទេ។

ចំពោះប្រសិទ្ធិផលនៃចំណុចទី៣ ទាក់ទងនឹងការពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ច្បាប់ [2] នោះនៅមិនទាន់សម្រេចបានពេញលេញនៅឡើយ។ ជំនួយរបស់ប្រទេសជប៉ុន គឺជាជំនួយដែលឆ្លងកាត់តាមរយៈអង្គការនិងស្ថាប័នជាច្រើន។ ការជម្រុញឲ្យមានវិធីដោះស្រាយវិវាទដែលអាចប្រើប្រាស់បានងាយស្រួលជាងមុន ដោយសារជំនួយបង្កើតស្ថាប័ន ADR នៅប្រទេសឥណ្ឌូនេស៊ី ត្រូវបានទទួលស្គាល់ថាមានការរីកចម្រើនមួយផ្នែកដោយសារជំនួយរបស់ជប៉ុន។ ដោយឡែក ចំពោះវិធានការសំដៅលើកកម្ពស់ការប្រើប្រាស់តុលាការរបស់ប្រជាពលរដ្ឋឯនោះវិញ ថ្វីត្បិតតែមានការអនុវត្តនូវជំនួយផ្នែកច្បាប់សម្រាប់ជនក្រីក្រដែលរៀបចំឡើងតាមរយៈគណៈមេធាវីក៏ដោយ ក៏គេមិនទាន់ទទួលស្គាល់បានជារួមថាជំនួយនានាក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋទូទៅនៅថ្នាក់មូលដ្ឋានបានទទួលសមិទ្ធិផលអ្វីជាសារវ័ននៅឡើយនោះទេ។

ក្នុងចំណោមសសរស្តម្ភទាំងបួនខាងលើនេះ ជំនួយបណ្តុះបណ្តាលធនធានមនុស្សទទួលបានភាពជោគជ័យជាងគេ។ ខណៈដែលការអប់រំផ្នែកនីតិសាស្ត្រនៅមិនទាន់មានរបៀបរៀបរយនិងកង្វះចំនួនអ្នកច្បាប់នៅជាបញ្ហាប្រឈមរបស់ប្រទេសទទួលជំនួយនេះ ជំនួយផ្នែកបណ្តុះបណ្តាលធនធានមនុស្សពីប្រទេសជប៉ុន អាចរួមចំណែកជួយកែលំអរបញ្ហាទាំងឡាយបានដោយផ្ទាល់។

ចុងក្រោយ ចំណោទបញ្ហាជារួមនៃការផ្តល់ជំនួយគឺ អំពើពុករលួយនៅក្នុងវិស័យយុត្តិធម៌។ ដោយសារប្រទេសទទួលជំនួយទាំងឡាយទើបតែកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ខ្លួនឲ្យក្លាយជាប្រព័ន្ធទំនើប ដូច្នេះ អំពើពុករលួយ គឺជាបញ្ហាដ៏ចម្បងមួយ។ ស្ថិតនៅក្នុងស្ថានភាពនៃការរីករាលដាលនៃអំពើពុករលួយ ប្រាក់កាស គឺជាកត្តាសម្រេចក្នុងវិស័យយុត្តិធម៌ដែលជាហេតុធ្វើឲ្យការជំនុំជម្រះមិនត្រូវបានដោះស្រាយតាមផ្លូវច្បាប់ និង មិនបានបង្ហាញនូវប្រសិទ្ធិភាពរបស់ស្ថាប័ន។ ហេតុនេះ ប្រសិទ្ធិផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់ក៏ពិបាកលេចចេញជារូបរាងបានដែរ។ ម្យ៉ាងទៀត នៅក្នុងអភិបាលកិច្ចល្អ ដែលជាគោលដៅចម្បងបំផុតនៃជំនួយរៀបចំប្រព័ន្ធច្បាប់ ការលុបបំបាត់អំពើពុករលួយគឺជាបញ្ហាមួយសំខាន់។ នាពេលអនាគត ការលុប

[2] ការពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ច្បាប់ គឺជាបេសកម្មធ្វើឲ្យប្រជាពលរដ្ឋទទួលបាននូវចំណេះដឹងអំពីច្បាប់ និងប្រព័ន្ធយុត្តិធម៌ដើម្បីអាចឈានទៅធ្វើការសម្រេចចិត្តនិងធ្វើសកម្មភាពផ្អែកលើឆន្ទៈផ្ទាល់ខ្លួន។ ក្នុងករណីដែលផលប្រយោជន៍របស់ខ្លួនត្រូវបានគេបំពាន ពួកគាត់អាចមានសមត្ថភាពស្វែងរកដោយខ្លួនឯងបាននូវដំណោះស្រាយតាមប្រព័ន្ធយុត្តិធម៌។

បំបាត់អំពើពុករលួយនៅប្រទេសទទួលជំនួយ គឺជាសមាសភាគដ៏ចាំបាច់ក្នុងការពង្រីកជាអតិបរមានូវសមិទ្ធផល និងឥទ្ធិពលនៃជំនួយ។





រូបថត៖ សមិទ្ធផលជំនួយរៀបចំប្រព័ន្ធច្បាប់របស់JICA នៅប្រទេសវៀតណាម

## ២.១.៣. ភាពត្រឹមត្រូវនៃដំណើរការ

ចំពោះភាពត្រឹមត្រូវនៃដំណើរការ យើងបានវាយតម្លៃជារួមយ៉ាងខ្ពស់ទៅលើស្ថានភាពនៃការពិភាក្សាយ៉ាងសមស្របជាមួយប្រទេសទទួលជំនួយ និង ការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ដែលមានកម្រិតជំនាញខ្ពស់ តាមរយៈការបញ្ជូនអ្នកជំនាញប្រកបដោយលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ដោយឡែក ការពិនិត្យទៅលើភាពត្រឹមត្រូវនៃដំណើរការបានបង្ហាញឲ្យឃើញពីបញ្ហាមួយចំនួន។ បញ្ហាទីមួយទាក់ទងនឹងការលំអរវិធីសាស្រ្ត និង រកដំណោះស្រាយលើបញ្ហាជាក់លាក់ជាក់លាក់មួយចំនួន។ ជាការជាក់ស្តែង គឺវាទាក់ទងនឹងបញ្ហាគួររៀបចំផែនការយ៉ាងសកម្មដើម្បីបញ្ចូលបន្ថែមនូវចក្ខុវិស័យ ដែលបានលើកឡើងក្នុងគោលនយោបាយសម្រាប់រយៈពេលកណ្តាលនិងគោលនយោបាយរួមរបស់ ODA ឲ្យបានទៅក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់ក្នុងនោះគួរមានការបញ្ចូលនូវវិធីសាស្រ្តសម្រាប់សម្រួលដល់ «ការបង្កើតគម្រោងអនុវត្តជំនួយដោយមានការពិចារណាទៅលើ “ការប្រឹងប្រែងផ្ទាល់ខ្លួនរបស់ប្រទេសកំពុងអភិវឌ្ឍន៍” និង “ការកាត់បន្ថយភាពក្រីក្រ”ដែលជាបញ្ហាត្រូវយកចិត្តទុកដាក់ជាចម្បង» ការកែលំអរអភិបាលកិច្ចឲ្យសម្រេចបាននូវ “ការធានាសន្តិសុខមនុស្សជាតិ”» និង «ការធានាសិទ្ធិរបស់ប្រជាពលរដ្ឋក្រីក្រឲ្យមានសមភាពចំពោះមុខច្បាប់សំដៅកាត់បន្ថយភាពក្រីក្រ» ។

យើងក៏បានវាយតម្លៃថា ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន បានធានានូវកិច្ចសហប្រតិបត្តិការជាមួយម្ចាស់ជំនួយផ្សេងទៀត និងស្ថាប័នអន្តរជាតិនានា ក្នុងកម្រិតមួយដែរ បើប្រៀបធៀបទៅនឹងជំនួយក្នុងវិស័យផ្សេងៗទៀត។ ប៉ុន្តែការសម្របសម្រួលជាមួយម្ចាស់ជំនួយផ្សេងទៀត មានភាពចាំបាច់យ៉ាងខ្លាំងនៅក្នុងការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ហេតុនេះយើងរំពឹងថានឹងមានការរៀបចំកិច្ចសហការឲ្យបានកាន់តែសកម្មជាងនេះទៀត។ លើសពីនេះ

យើងក៏រំពឹងថាប្រទេសជប៉ុននឹងរៀបចំកិច្ចសហការ យ៉ាងសកម្មជាមួយបណ្តាម្ចាស់ជំនួយពហុភាគីដែលប្រទេសជប៉ុនបានឧបត្ថម្ភជាថវិកាផងដែរនោះ។

ចំពោះប្រព័ន្ធអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់នាពេលអនាគតវិញ ដើម្បីឲ្យការអនុវត្តជំនួយបន្តប្រព្រឹត្តទៅបានល្អ យើងគិតថាចាំបាច់ត្រូវដោះស្រាយបញ្ហានានាទាក់ទងនឹងកម្រៃជូនអ្នកជំនាញការ ថ្លៃសេវា និងបញ្ហានៃប្រព័ន្ធជួយជ្រោមជ្រែងពីស្ថាប័នបញ្ជូនអ្នកជំនាញការដូចជាអង្គការនានាទាក់ទងនឹងមេធាវី ជាដើម។

ជាចំណុចចុងក្រោយ យើងគិតថាដោយសារជំនួយរៀបចំប្រព័ន្ធច្បាប់នាពេលអនាគតនឹងឈានដល់ដំណាក់កាលជំនួយលើការអនុវត្តច្បាប់ទាំងមូល ដោយរួមបញ្ចូលទាំងច្បាប់ដែលបានតាក់តែងឡើងកន្លងមក តាមរយៈជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនដែរ។ ដូច្នេះបញ្ហាចោទឡើងស្របគ្នានោះដែរ គឺ ការកសាងនូវប្រព័ន្ធតាមដានពិនិត្យអំពីស្ថានភាពនៃការអនុវត្តច្បាប់ទៅក្នុងក្របខ័ណ្ឌនៃជំនួយរៀបចំប្រព័ន្ធច្បាប់នេះឯង។

ការលើកឡើងបែបនេះមិនមែនមានន័យថា ជាការវាយតម្លៃអវិជ្ជមានអំពីភាពត្រឹមត្រូវនៃដំណើរការកន្លងមកនោះទេ ប៉ុន្តែ យើងសូមបញ្ជាក់បន្ថែមទៀតថាបញ្ហាទាំងនេះបានលេចចេញពីមេរៀនជាច្រើនដែលទទួលបាន តាមរយៈការផ្តល់ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនជាង២០ឆ្នាំកន្លងមកនេះ ហើយនិងជាបញ្ហាដែលចោទឡើងពីការប្រាថ្នាចង់លើកកំពស់ប្រសិទ្ធិផលនៃជំនួយនាពេលអនាគត ក្នុងខណៈដែលជំនួយកំពុងតែងាកចេញពីការប្រមូលផ្តុំលើការតាក់តែងច្បាប់ និង ការបណ្តុះបណ្តាលធនធានមនុស្សជាបង្គោលឆ្ពោះទៅរកការយកចិត្តទុកដាក់អំពីការដោះស្រាយការអនុវត្តច្បាប់ជាក់ស្តែងនោះ។ យោងតាមអ្វីដែលបានរៀបរាប់ខាងលើ យើងសូមវាយតម្លៃថា ក្នុងទស្សនៈនៃភាពត្រឹមត្រូវនៃដំណើរការជំនួយ គឺជំនួយរៀបចំប្រព័ន្ធច្បាប់កន្លងមកបានអនុវត្តយ៉ាងត្រឹមត្រូវមួយកម្រិតដែរ ។






រូបថត៖ សកម្មភាពពិភាក្សាក្រុម (ឆ្វេង) និង កិច្ចប្រជុំនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ (ស្តាំ)

### ២.១.៤. ការវាយតម្លៃក្នុងទស្សនៈគោលនយោបាយការទូត

ជារួម ជំនួយរៀបចំប្រព័ន្ធច្បាប់ ពិតជាបានរួមវិភាគទានជាច្រើនទៅលើវិស័យការទូតរបស់ប្រទេសជប៉ុន។ លក្ខណៈពិសេសមួយ គឺការបង្កឲ្យមានបណ្តាញទាក់ទងគ្នាយ៉ាងរឹងមាំខាងធនធានមនុស្ស ហើយតាមរយៈជំនួយនេះ អ្នកដែលយល់ដឹងនិងធ្លាប់ទាក់ទងស្និតស្នាលជាមួយប្រទេសជប៉ុនច្រើនតែក្លាយជាអ្នកមានតំណែង ឬ តួនាទីសំខាន់ៗក្នុងស្ថាប័នរដ្ឋបាលនានា និង ក្នុងសង្គមសេដ្ឋកិច្ច។ ចំណុចនេះក៏ត្រូវបានលើកឡើងនៅក្នុងកិច្ចចរចារថ្នាក់កំពូលនិងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ព្រមទាំងជាការផ្សាភ្ជាប់ទំនាក់ទំនងរវាងប្រទេសទាំងពីរឲ្យកាន់តែជិតស្និត។ ជំនួយរៀបចំប្រព័ន្ធច្បាប់ គឺជាធាតុផ្សំដ៏សំខាន់ក្នុងការរៀបចំមូលដ្ឋានសម្រាប់បរិយាកាសវិនិយោគហើយសមិទ្ធផលដែលទទួលបានពីជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន ទាំងខាងស្ថាប័ន ទាំងខាងធនធានមនុស្ស សុទ្ធតែសំដៅទៅជម្រុញដោយប្រយោលដើម្បីឲ្យសហគ្រាសជប៉ុនមកបោះទុនវិនិយោគនៅប្រទេសទទួលជំនួយ។ ប៉ុន្តែ ដោយហេតុថា សហគ្រាសជប៉ុនមិនសូវដឹងពីចំណុចនេះទេ យើងរំពឹងថា វានឹងចូលរួមចំណែកនាំមកនូវប្រយោជន៍ជូនសហគ្រាសជប៉ុនដោយផ្ទាល់ តាមរយៈកិច្ចសហការផ្អែកលើកិច្ចព្រមព្រៀងជាដៃគូសេដ្ឋកិច្ច (EPA) រវាងជប៉ុននិងប្រទេសទទួលជំនួយនោះជាដើម។ ជាងនេះទៅទៀត ប្រទេសម្ចាស់ជំនួយផ្សេងៗ ក៏បានទទួលស្គាល់នូវសមិទ្ធផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនផងដែរ។ នេះកំពុងតែលើកតម្កើននូវវត្តមានជំនួយរបស់ប្រទេសជប៉ុន។ សរុបមក យើងអាចសន្និដ្ឋានថា ជំនួយរៀបចំប្រព័ន្ធច្បាប់បានផ្តល់នូវសារៈប្រយោជន៍ខាងផ្នែកនយោបាយ ផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច ផ្នែកសិក្សាបច្ចេកទេសរបស់ប្រទេសទាំងសងខាងទន្ទឹមនឹងការពង្រីកអំណាចទន់ ហើយនិងលើកតម្កើនដល់វត្តមានរបស់ប្រទេសជប៉ុនលើឆាកអន្តរជាតិទៀតផង។

## ២.២. អនុសាសន៍ផ្អែកលើការវាយតម្លៃ

### ២.២.១. អនុសាសន៍

អនុសាសន៍ដោយផ្អែកលើគម្រោងវាយតម្លៃនេះ មានខ្លឹមសារដូចខាងក្រោម។ ជំនួយរៀបចំប្រព័ន្ធច្បាប់ បានឆ្លងពីដំណាក់កាលជំនួយតាក់តែងច្បាប់ និង ជំនួយក្នុងវិស័យយុត្តិធម៌ដែលជាជំនួយរៀបចំប្រព័ន្ធច្បាប់ជាមូលដ្ឋាននិងស្ថាប័ននានា ទៅកាន់ដំណាក់កាលមួយទៀតដែលជួយលើកស្ទួយឲ្យជនទាំងឡាយក្នុងប្រទេសទទួលជំនួយផ្ទាល់អាចចាត់ចែង និង អនុវត្តច្បាប់ ដោយអនុញ្ញាតឲ្យច្បាប់ និងស្ថាប័នទាំងនោះ អាចដំណើរការស្របតាមតួនាទីដើមបានដោយឆ្លងតាមរយៈដំណើរការនៃប្រព័ន្ធតុលាការ។ នេះដោយសារមូលហេតុថា គោលបំណងចម្បងបំផុតនៃជំនួយរៀបចំប្រព័ន្ធច្បាប់ គឺការសម្រេចឲ្យបាននូវនីតិរដ្ឋ និង ការជានាសន្តិសុខ

មនុស្សជាតិ ដូច្នេះគួរតែមានការពង្រឹងឲ្យបានជិតដល់ក្នុងការសម្រួលដល់ប្រជាពលរដ្ឋឲ្យឈាន ទៅប្រើប្រាស់ប្រព័ន្ធតុលាការបានសមស្រប។ យើងសូមបញ្ជាក់បន្ថែមទៀតថា ការអនុវត្តតាម អនុសាសន៍ទាំងឡាយដែលបានលើកឡើងក្នុងទស្សនៈខាងលើនេះ ត្រូវផ្អែកលើការទុកចិត្តគ្នា ទៅវិញទៅមក ដែលបានកសាងឡើងជាមួយប្រទេសទទួលជំនួយនាពេលកន្លងមក ហើយក្នុង ករណីខ្លះ នៅពេលអនុវត្តច្បាប់ យើងចាំបាច់ត្រូវពិចារណាឲ្យបានហ្មត់ចត់ទៅលើស្ថានភាព ជាក់ស្តែងទាក់ទងនឹងប្រព័ន្ធនយោបាយនៃប្រទេសទទួលជំនួយនីមួយៗនិងស្ថានភាពការជំនួយ រៀបចំប្រព័ន្ធច្បាប់ក្នុងប្រទេសទាំងនោះជាដើម និង ត្រូវធ្វើការពិភាក្សាចាំបាច់ជាមួយក្រុមអ្នក ដែលមានការពាក់ព័ន្ធទាំងឡាយនៅក្នុងជួររដ្ឋាភិបាល ស្ថាប័នយុត្តិធម៌ ស្ថាប័នអន្តរជាតិ NGO សហគ្រាសនានា និង សាកលវិទ្យាល័យនៃប្រទេសទទួលជំនួយជាអាទិ៍ ដោយផ្អែកលើទស្សនៈ នៃការសិក្សាអំពីបញ្ហាក្នុងតំបន់ និងផ្អែកលើគោលគំនិតនៃនីតិសង្គមវិជ្ជា និងនីតិសាស្ត្រអាស្រ័យ នវិជ្ជា។

### (១) ការបង្កើតឲ្យមានវេទិកាប្រឹក្សាអំពីគោលនយោបាយនៅថ្នាក់កំពូល

ដូចដែលបានរៀបរាប់នៅក្នុងការវាយតម្លៃខាងលើ ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ ប្រទេសជប៉ុនត្រូវបានទទួលនូវការវាយតម្លៃខ្ពស់ បើប្រៀបធៀបជាមួយប្រទេសម្ចាស់ជំនួយដទៃ ទៀត ព្រមទាំងទទួលបានការវាយតម្លៃប្រសិទ្ធិផលខ្ពស់ ខាងផ្នែកការទូតទៀតផង។ នាពេល អនាគត បើជំនួយរៀបចំប្រព័ន្ធច្បាប់ចេញជាផ្លែផ្កា មិនត្រឹមតែរដ្ឋាភិបាលនៃប្រទេសទទួលជំនួយ ទេដែលទទួលបានផលប្រយោជន៍ ពេលនោះសហគ្រាសជប៉ុន សហគ្រាសបរទេស និង រដ្ឋាភិបាលនៃប្រទេសជុំវិញនោះក៏ទទួលបានផលប្រយោជន៍ផងដែរ។ បន្ថែមពីនេះទៀតដោយ សារតែជំនួយក្នុងការរៀបចំប្រព័ន្ធច្បាប់អាចជម្រុញដោយផ្ទាល់ចំពោះការរៀបចំនូវនីតិរដ្ឋនិងការ ធានាសន្តិសុខមនុស្សជាតិ ដែលជាសសរស្តម្ភសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ ប្រទេសជប៉ុននោះ នាពេលអនាគត ការពង្រីកបន្ថែមនៃជំនួយរៀបចំប្រព័ន្ធច្បាប់ទាំងក្នុងក្រប ខ័ណ្ឌយុទ្ធសាស្ត្រ និងគោលនយោបាយ ហើយធ្វើការផ្សព្វផ្សាយពីប្រសិទ្ធិផលនៃជំនួយឲ្យបាន ដឹងឮជាអន្តរជាតិ អាចមានអត្ថន័យសំខាន់ដល់គោលនយោបាយការទូតរបស់ប្រទេសជប៉ុនបាន ដែរ។

ដើម្បីឲ្យការយល់ដឹងពីគោលបំណងនៃគោលនយោបាយនេះ កាន់តែស៊ីជម្រៅថែម ទៀតរដ្ឋាភិបាលថ្នាក់កំពូលរបស់ប្រទេសជប៉ុន ត្រូវបង្កើតឲ្យមានវេទិកាសម្រាប់ពិនិត្យអំពីជំនួយ រៀបចំប្រព័ន្ធច្បាប់ និង រៀបចំគោលនយោបាយឲ្យបានយ៉ាងសកម្មភាព និង ឲ្យបានញឹកញប់។ ចំណុចសំខាន់គឺការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ដែលមានលក្ខណៈឆ្លងស្ថាប័ន និង ប្រកប ដោយភាពរស់រវើក ចូលរួមដោយមន្ត្រីរាជការ និងអ្នកពាក់ព័ន្ធ ក្នុងផ្នែករដ្ឋ និង ផ្នែកឯកជន សម្រួលដល់ការរៀបចំគោលនយោបាយកម្រិតថ្នាក់កំពូល (គណៈរដ្ឋមន្ត្រី ជាអាទិ៍)។ ក្នុង ស្ថានភាពបច្ចុប្បន្ន យើងឃើញមានវេទិកាមួយចំនួនដែលអាចប្រើបាន ដូចជា “កិច្ចប្រជុំការងារ

ទំនាក់ទំនងរៀបចំប្រព័ន្ធច្បាប់” “កិច្ចប្រជុំយុទ្ធសាស្ត្រស្តីពីរចនាសម្ព័ន្ធក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច” និង “ជំនួយសហគ្រាសជប៉ុនទាក់ទងនឹងនីតិកម្មអន្តរជាតិ” ជាដើម។ ទន្ទឹមនឹងការបន្តប្រើប្រាស់នូវវេទិកាទាំងនេះ យើងគិតថាគួរមានការពិនិត្យ និងពិភាក្សា ពីសំណាក់ថ្នាក់ដឹកនាំខ្ពស់ជាងនេះថែមទៀតទើបជាការប្រសើរ។

ការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ ដោយមានកិច្ចសហការរវាងផ្នែករដ្ឋ និង ផ្នែកឯកជន អាចធ្វើឲ្យជំនួយនោះប្រព្រឹត្តទៅបានកាន់តែរហ័សនិងមានភាពបត់បែន ធ្វើឲ្យប្រសិទ្ធិភាពនៃ ODA កាន់តែប្រសើរឡើង[3] ហើយអាចនាំមកនូវសញ្ញាវិជ្ជមាន ចំពោះទំនាក់ទំនងការទូតរបស់ប្រទេសជប៉ុនផងដែរ។

### (២) ការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ចំពោះស្ថាប័នដែលមានសិទ្ធិសម្រេចពីគោលនយោបាយ

ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនរហូតមកទល់ពេលនេះ ផ្តោតសំខាន់លើស្ថាប័នអនុវត្តក្នុងនាមជាស្ថាប័នទទួលបន្ទុកដោយផ្ទាល់ ចំពោះការរៀបចំប្រព័ន្ធច្បាប់ ជាក់ស្តែងដូចដែលមានអនុវត្តនៅក្នុងក្រសួងយុត្តិធម៌នៃប្រទេសវៀតណាម និង ក្រសួងយុត្តិធម៌នៃប្រទេសកម្ពុជាជាដើម។ ជំនួយរៀបចំប្រព័ន្ធច្បាប់ក្នុងកម្រិតបែបនេះ ច្បាស់ជានឹងមានរួមចំណែកក្នុងការកសាងប្រព័ន្ធគ្រប់គ្រងរដ្ឋ ដោយផ្អែកលើគោលការណ៍នីតិរដ្ឋតាមរយៈជំនួយតាក់តែងច្បាប់មូលដ្ឋាននិងការបណ្តុះបណ្តាលធនធានអ្នកច្បាប់ ដូចជា ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីជាដើម។ ការផ្តល់ជំនួយរៀបចំប្រព័ន្ធច្បាប់បែបនេះ នៅបន្តមានសារៈសំខាន់តទៅទៀត សម្រាប់ជួយពង្រឹងនីតិរដ្ឋ នៅប្រទេសទទួលជំនួយ។

ប៉ុន្តែ មានការលើកឡើងនូវបញ្ហាមួយចំនួន ចំពោះការសម្រេចលទ្ធផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន ដូចមានបង្ហាញជូនក្នុងការវាយតម្លៃនេះស្រាប់។ ដើម្បីទទួលបានលទ្ធផលដូចបានរំពឹងទុកនៅមុនពេលអនុវត្តគម្រោង និង ក្នុងពេលដំណើរការគម្រោង យើងត្រូវធ្វើការចរចារយ៉ាងជាប់លាប់ជាមួយនឹងស្ថាប័នដែលមានសិទ្ធិសម្រេចអំពីគោលនយោបាយនានានៅប្រទេសទទួលជំនួយ។ ជាពិសេស ចំពោះជំនួយតាក់តែងច្បាប់ចាំបាច់ត្រូវមានការបំពាក់បំប៉នឲ្យមានការយល់គ្នា និង ការគ្រាំទ្រ តាមរយៈការពន្យល់ក្បោះក្បាយ និងការពិភាក្សាជជែកដេញដោលទាក់ទងនឹងគោលគំនិតច្បាប់ថ្មីដែលនឹងត្រូវណែនាំទៅកាន់ប្រទេសទទួលជំនួយ។

ម្យ៉ាងទៀត អំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ គឺជាជញ្ជាំងភ្លើងដ៏ធំមួយដែល

---

[3] ដោយសារតែសព្វថ្ងៃនេះនៅប្រទេសជប៉ុន មានក្រសួងជាច្រើនពាក់ព័ន្ធនៅក្នុងជំនួយ ឧទាហរណ៍ដូចជា ក្រសួងការបរទេសដែលទទួលខុសត្រូវចំពោះជំនួយទ្វេភាគី ចំណែកឯក្រសួងហិរញ្ញវត្ថុទទួលខុសត្រូវចំពោះជំនួយផ្នែកហិរញ្ញវត្ថុតាមរយៈអង្គការអភិវឌ្ឍន៍ហិរញ្ញវត្ថុនានា។ ក្នុងន័យនេះ ប្រសិនបើបើកឲ្យមានការចរចារគ្នាចំពោះជំនួយរៀបចំប្រព័ន្ធច្បាប់នៅថ្នាក់កំពូល និង កិច្ចសហការរវាងក្រសួងផ្សេងៗ យើងរំពឹងថា ការអនុវត្តជំនួយនឹងមានប្រសិទ្ធិភាពកើនឡើង។

ខ័ណ្ឌចែកមិនឲ្យយើងមើលឃើញនូវប្រសិទ្ធិផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់។ ដោយយល់ឃើញទិសដៅនៃការលុបបំបាត់អំពីពុករលួយ និងការសូកប៉ាន់ត្រូវបានចែងក្នុង គោលនយោបាយជំនួយរបស់ប្រទេសជប៉ុនដូចជាក្នុងគោលការណ៍សំខាន់ៗរបស់ ODA នោះ យើងអាចនិយាយបានថា ក្នុងក្របខ័ណ្ឌនៃជំនួយរៀបចំប្រព័ន្ធច្បាប់នេះ ក៏ត្រូវតែមានការរៀបចំជាយុទ្ធសាស្ត្រក្នុងទម្រង់ជាក់លាក់ណាមួយ ដើម្បីជួយទប់ស្កាត់អំពើពុករលួយ[4] ផងដែរ។ លើសពីនេះ បើសង្កេតមើលលើគោលការណ៍រួមរបស់ ODA និង គោលនយោបាយរយៈពេលកណ្ដាលរបស់ ODA ដែលមានគោលដៅកែសម្រួលអភិបាលកិច្ចល្អ និងឈរលើគោលជំហរធានាសន្តិសុខមនុស្សជាតិ និង គោរពសមភាពយែនឌ័រ យើងត្រូវធ្វើឲ្យមានភាពប្រាកដថាប្រជាពលរដ្ឋគ្រប់រូបនៅប្រទេសទទួលជំនួយ បានទទួលនូវផលប្រយោជន៍តាមរយៈជំនួយរៀបចំប្រព័ន្ធច្បាប់។ ផ្អែកលើស្ថានភាពបែបនេះ យើងគួរពិចារណាពីភាពចាំបាច់ត្រូវ មានការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ ចំពោះស្ថាប័នដែលមានសិទ្ធិសម្រេចលើគោលនយោបាយនានាផងដែរ ជាការបន្ថែមលើជំនួយបច្ចុប្បន្នដែលកំពុងផ្ដល់ទៅកាន់ស្ថាប័នអនុវត្តជំនាញ។

ឧទាហរណ៍ យុទ្ធសាស្ត្រមួយ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ គឺការផ្សព្វផ្សាយសាលក្រមជាសាធារណៈ។ តាមរយៈការផ្សព្វផ្សាយបែបនេះ យើងនឹងអាចពង្រឹងតម្លាភាពក្នុងការវិនិច្ឆ័យតាមគតិយុត្តិធម៌របស់ចៅក្រម ជាដើម ព្រមទាំងអាចពង្រឹងនីតិរដ្ឋបានបន្ថែមទៀត។ ការងារនេះ ទាមទារឲ្យមានការផ្ដល់ជាជំនួយចំពោះគម្រោងនៃស្ថាប័នអនុវត្តជំនាញ និង ការអនុវត្តគម្រោងនៅថ្នាក់មូលដ្ឋាន។ ប៉ុន្តែ ជាការអនុវត្តជាក់ស្ដែង អាចមានការរារាំងទប់ស្កាត់ពីមជ្ឈដ្ឋានអំណាចដែលពាក់ព័ន្ធនឹងអំពើពុករលួយ។ គេមានការព្រួយបារម្ភថា នេះនឹង ធ្វើឲ្យជំនួយនៅថ្នាក់មូលដ្ឋានមិនអាចសម្រេចបាននូវផ្លែផ្កាល្អឡើយ។ ដូច្នេះ គម្រោងនេះត្រូវចាប់ដំណើរការជាមួយ ស្ថាប័ននយោបាយថ្នាក់មជ្ឈឹមដោយមានការគាំទ្រអំពីការអនុវត្តគោលនយោបាយលុបបំបាត់អំពើពុករលួយក្នុងប្រព័ន្ធយុត្តិធម៌ពីថ្នាក់លើទៅថ្នាក់ក្រោម ដើម្បីអាចលុបបំបាត់ការជ្រៀតជ្រែងពីសំណាក់អ្នកមានអំណាចនៅតាមមូលដ្ឋាន។ នេះគ្រាន់តែជាឧទាហរណ៍មួយទេ ប៉ុន្តែបើសិនជាអាចបំពេញនូវលក្ខខណ្ឌបែបនេះបាន ដោយប្រាស្រ័យទាក់ទងផ្ទាល់ទៅនឹងស្ថាប័នដែលមានសិទ្ធិសម្រេចពីគោលនយោបាយនោះ វាប្រាកដជាហុចផ្លែផ្កាដល់ ជំនួយរៀបចំប្រព័ន្ធច្បាប់ដែលជប៉ុន កំពុងតែអនុវត្តយ៉ាងមានលទ្ធផលល្អនៅថ្នាក់មូលដ្ឋាន។

តាមរយៈការបង្ខិតទៅជិតស្ថាប័ននយោបាយថ្នាក់មជ្ឈឹម អាចមានការបារម្ភផងដែរថា ជំនួយអាចនឹងបាត់បង់ភាពអព្យាក្រឹត្យរបស់វា។ ប៉ុន្តែ ទោះបីជាដំណើរការនៃការបង្ខិតទៅ

[4] តាំងពីដើមមក ជំនួយរបស់ JICA ក៏មានលើកឡើងនូវវិធីសាស្ត្រនានាក្នុងការទប់ស្កាត់អំពើពុករលួយដែរ ប៉ុន្តែតាមរយៈការរួមបញ្ចូលការទប់ស្កាត់អំពើពុករលួយក្នុងក្របខ័ណ្ឌនៃការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ យើងអាចជម្រុញឲ្យលទ្ធផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់ចេញជារូបរាងឡើងបាន។

ជិតស្ថាប័នមានអំណាចសម្រេចពីគោលនយោបាយ បានប្រព្រឹត្តឡើងនៅក្នុងកម្រិតមួយក៏ដោយ ក៏ប្រទេសជប៉ុននៅតែចាំបាច់ទទួលខុសត្រូវចំពោះឥទ្ធិពលនានាដែលកើតពីជំនួយរៀបចំប្រព័ន្ធច្បាប់មកទល់នឹងពេលបច្ចុប្បន្ននេះដែរ ហើយត្រូវផ្តល់ជូននូវអនុសាសន៍សមស្របទៅកាន់ប្រទេសជាដៃគូ ដោយផ្អែកលើជំនឿទុកចិត្តគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរ។ ម៉្យាងវិញទៀត បើសិនជាអព្យាក្រឹត្យភាពនៃជំនួយមិនអាចរក្សាបានទេនោះ នៅមានយុទ្ធសាស្ត្រមួយទៀតគឺ ត្រូវបង្កើតគម្រោងសហប្រតិបត្តិការជាពហុភាគីជាមួយម្ចាស់ជំនួយផ្សេងទៀត ដោយបន្តរក្សានូវផ្នែកណាមួយនៃគោលនយោបាយជំនួយរបស់ប្រទេសជប៉ុននៅក្នុងនោះ។

ក្នុងការចុះស្រាវជ្រាវដល់ទីកន្លែងនៅប្រទេសទទួលជំនួយដើម្បីធ្វើការវាយតម្លៃលើកនេះ យើងឃើញថា ស្ថាប័នដែលមានអំណាចសម្រេចពីគោលនយោបាយ (ពោលគឺគណកម្មធិការកណ្តាលនៃគណបក្សកុំម្មុយនីសវៀតណាម) បានប្រាថ្នាចង់ឲ្យជប៉ុនអនុវត្តជំនួយ ចំពោះមជ្ឈដ្ឋានអ្នករៀបចំគោលនយោបាយ។ ក្នុងករណីនេះជប៉ុនគួរតែពិចារណា និងព្យាយាមអនុវត្តតាម។

### (៣) ការអនុវត្តជំនួយតាមដានស្ថានភាពនៃការអនុវត្តច្បាប់

ដោយហេតុថាជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន កំពុងខិតចេញពីការរៀបចំប្រព័ន្ធច្បាប់និងការបណ្តុះបណ្តាលធនធានមនុស្ស ទៅរកការសង្កត់ធ្ងន់លើការអនុវត្តច្បាប់វិញ ការតាមដានស្ថានភាពនៃការអនុវត្តច្បាប់ទាំងនោះ ក៏ជាបេសកម្មមិនអាចខ្វះបានផងដែរ។ ជាអកុសល រហូតមកដល់ពេលបច្ចុប្បន្ននេះ ដោយសារតែប្រទេសជប៉ុនមានភាពយឺតយ៉ាវក្នុងការរៀបចំព័ត៌មានទាក់ទងនឹងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសទទួលជំនួយ ដែលជាហេតុធ្វើឲ្យមានភាពលំបាកក្នុងការតាមដានស្ថានភាពនៃការអនុវត្តច្បាប់។ ដោយឡែកនៅក្នុងការពិភាក្សាអំពីភាពសមស្របនៃដំណើរការខាងលើ យើងឃើញមានការលើកឡើងពីគោលបំណងចង់ឲ្យឈានទៅកាន់ «ការកែលំអរនូវអភិបាលកិច្ចដើម្បីធានាសន្តិសុខមនុស្សជាតិ» និង «ការគាំពារសិទ្ធិរបស់ប្រជាពលរដ្ឋក្រីក្រ»យ៉ាងសកម្មតាមរយៈការរៀបចំប្រព័ន្ធច្បាប់នោះ យើងសូមផ្តល់អនុសាសន៍ថា គួរតែមានការតាមដានលទ្ធផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់ដោយមើលលើករណីនៃការកាត់បន្ថយភាពក្រីក្រ និង សមភាពយេនឌ័រទើបជាការប្រសើរ។

បើពិចារណាលើទិដ្ឋភាពដែលបានលើកឡើងខាងលើ យើងអាចគិតគូរបន្ថែមនូវទិដ្ឋភាពមួយទៀតគឺ ជំនួយរៀបចំព័ត៌មានសម្រាប់តាមដានការអនុវត្តច្បាប់ ចំពោះការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ពេលក្រោយៗទៀត[5] ។ ក្នុងឱកាសនេះត្រូវផ្តោតសំខាន់លើការយល់

[5] នេះមិនមែនជាការតាមដានចំពោះលទ្ធផលនៃគម្រោងរបស់អង្គការ JICA ទេ។ វាមានគោលបំណងពិនិត្យដើម្បីបញ្ជាក់អំពីប្រសិទ្ធិផលទូលំទូលាយរបស់ជំនួយរៀបចំប្រព័ន្ធច្បាប់ទៅលើជីវភាពរបស់ប្រជាពលរដ្ឋ (តាមរយៈការពិនិត្យស្ថានភាពប្រើប្រាស់ប្រព័ន្ធតុលាការ និង ស្ថានភាពពិគ្រោះយោបល់ជាមួយមេធាវី)។

ឃើញពីជ្រុងទស្សនៈរបស់ប្រជាពលរដ្ឋទូទៅផងដែរ ក្នុងការតាមដានស្ថានភាពនៃការអនុវត្តច្បាប់នៅតាមមូលដ្ឋានសង្គមទូទៅ។ ដើម្បីធ្វើបានយ៉ាងដូច្នេះ ប្រទេសជប៉ុនត្រូវពិចារណាបន្ថែមពីលើកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសដែលមានស្រាប់ដោយប្រើប្រាស់នូវគម្រោងជំនួយផ្សេងទៀតដែលខ្លួនមាន (ឧទាហរណ៍ ការប្រើប្រាស់តាមលទ្ធភាពដែលអាចធ្វើទៅបាននូវជំនួយឥតសំណងនានាដែលជាឱកាសសម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រជាពលរដ្ឋ និងជំនួយសម្រាប់ផ្តល់ទៅអង្គការ NGO ជាដើម ដើម្បីផ្តល់ព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយធ្វើការតាមដានការចូលរួមរបស់ប្រជាពលរដ្ឋទូទៅ នៅក្នុងវិស័យយុត្តិធម៌ ព្រមទាំងតាមដានស្ថានភាពនៃការអនុវត្តច្បាប់ជាក់ស្តែងរបស់តុលាការផងដែរ)។ សកម្មភាពនេះ ត្រូវប្រព្រឹត្តឡើងតាមរយៈការប្រើប្រាស់ធនធានមនុស្សរបស់ សម្ព័ន្ធគណៈមេធាវីជប៉ុន ដែលជាអង្គភាពឯករាជ្យពីក្រសួងការបរទេសនិង JICA ព្រមទាំងប្រើប្រាស់ធនធានមនុស្សរបស់ NGO ក្នុងស្រុកនិងក្រៅស្រុកនានា និង ធនធានមនុស្សនៅតាមសាកលវិទ្យាល័យ។ ព្រមទាំង ជម្រុញឲ្យមានការបញ្ចេញមតិយោបល់តប និង ពិនិត្យផ្ទៀងផ្ទាត់ តាមរយៈកិច្ចសហការជាមួយគម្រោងកម្មវិធីនៃសិទ្ធិទទួលបានយុត្តិធម៌ ដែលរៀបចំឡើងដោយ ស្ថាប័នអន្តរជាតិនានា ដូចជា UNDP World Bank ជាដើម។ ជាងនេះទៅទៀត ការតាមដានចំពោះស្ថានភាពនៃការបន្តបង្កើននូវចំណេះដឹងរបស់ធនធានអ្នកច្បាប់ដែលបានបណ្តុះបណ្តាលកន្លងមក ក៏ជាគម្រោងមួយដែលផ្តល់ផលប្រយោជន៍ច្រើនផងដែរ។

### (៤)ការពង្រឹងសកម្មភាពផ្សព្វផ្សាយដើម្បីជម្រុញនិងសម្រួលដល់ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌និងច្បាប់

ដូចបានបញ្ជាក់ក្នុងចំណុចស្តីពីប្រសិទ្ធិផលនិងភាពសមស្របនៃដំណើរការរួចហើយ បញ្ហាដ៏ធំមួយនៃការបង្កើនប្រសិទ្ធិផលរបស់ជំនួយរៀបចំប្រព័ន្ធច្បាប់ គឺការកែលំអរទៅលើការប្រើប្រាស់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយប្រជាពលរដ្ឋសាមញ្ញ។ មូលហេតុចម្បងនៃបញ្ហានេះ គឺមកពីប្រជាពលរដ្ឋទូទៅមិនទាន់បានព័ត៌មានគ្រប់គ្រាន់ អំពីការរៀបចំប្រព័ន្ធច្បាប់ក្រោមជំនួយរបស់ប្រទេសជប៉ុននៅឡើយទេ។ ដើម្បីកែលំអរស្ថានភាពនេះ យើងត្រូវមានការផ្សព្វផ្សាយអំពីប្រព័ន្ធយុត្តិធម៌យ៉ាងសកម្មនិងជាសាធារណៈដោយប្រើប្រព័ន្ធផ្សព្វផ្សាយផ្សេងៗរបស់ប្រទេសនីមួយៗ។

ទាក់ទងនឹងការពង្រឹងសកម្មភាពផ្សព្វផ្សាយនេះ ក្រៅពីមធ្យោបាយផ្សព្វផ្សាយតាមរយៈស្ថាប័នការទូតរបស់ជប៉ុននៅប្រទេសនីមួយៗ យើងត្រូវពិចារណាផងដែរអំពី ការរៀបចំចងក្រង និង ចែកជូននូវឯកសារ ការផ្តល់ជំនួយសម្រាប់សកម្មភាពផ្សព្វផ្សាយនៅក្នុងគម្រោងសហប្រតិបត្តិការបច្ចេកទេសនានារបស់JICA និងការពន្យល់ប្រជាពលរដ្ឋឲ្យបានជ្រួយជ្រាប

អំពីការប្រើប្រាស់ច្បាប់ និងប្រព័ន្ធយុត្តិធម៌តាមរយៈការជួយសម្រួលសកម្មភាពរបស់ NGO[6]។

ស្របជាមួយនឹង «ការអនុវត្តជំនួយតាមដានស្ថានភាពនៃការអនុវត្តច្បាប់» ដែលបានលើកឡើង នៅក្នុងចំណុច (៣) ខាងលើ ស្ថាប័នរដ្ឋាភិបាលនៃប្រទេសទទួលជំនួយត្រូវទទួលខុសត្រូវចំពោះ សកម្មភាពតាមដានស្ថានភាព និង ពន្យល់បំភ្លឺអំពីការអនុវត្តច្បាប់។ ម៉្យាងទៀត យើងមានការព្រួយបារម្ភថានឹងមិនអាចឆ្លើយតបទៅនឹងមន្ទិលសង្ស័យនានាពីសំណាក់ស្ថាប័នពាក់ព័ន្ធ ដែលចោទសួរអំពីលទ្ធផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនបាន ប្រសិនបើការតាមដានស្ថានភាពនិងការពន្យល់បំភ្លឺអំពីការអនុវត្តច្បាប់មិនមានលក្ខណៈសមស្របទេនោះ។ ការផ្តល់អនុសាសន៍នេះ គឺ ផ្អែកលើការត្រិះរិះពិចារណាចំពោះសារៈសំខាន់នៃការបង្ហាញឲ្យបានជាក់លាក់នូវលទ្ធផលល្អៗនៃជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន ។

### (៥) ការពង្រឹងនូវទំនាក់ទំនងជាមួយម្ចាស់ជំនួយផ្សេងទៀត និង អង្គការអន្តរជាតិនានា

ជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន ទទួលបាននូវការវាយតម្លៃខ្ពស់និងភាពលេចធ្លោតាមការប្រៀបធៀប ដោយសារមានការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ផ្អែកលើមូលដ្ឋាននៃការបញ្ជូនអ្នកជំនាញការរយៈពេលវែង។ យើងគួរប្រើប្រាស់ភាពលេចធ្លោតាមការប្រៀបធៀបនេះ ជាមគ្គុទេសន៍ណែនាំសម្រាប់ជំនួយរៀបចំប្រព័ន្ធច្បាប់ដែលធ្វើឡើងដោយម្ចាស់ជំនួយទាំងអស់ឲ្យបានយ៉ាងសកម្ម។ ធ្វើយ៉ាងនេះ យើងក៏អាចលើកស្ទួយបានមួយកម្រិតថែមទៀតនូវសារៈសំខាន់នៃវត្តមានជំនួយជប៉ុនក្នុងការរៀបចំប្រព័ន្ធច្បាប់ផងដែរ។ ម៉្យាងទៀត ដោយសារកង្វះខាតនូវការសម្របសម្រួលជាមួយនឹងម្ចាស់ជំនួយដូចដែលបានលើកឡើងក្នុង ចំណុចស្តីពីភាពត្រឹមត្រូវនៃដំណើរការដែលធ្វើឲ្យមានផលប៉ះពាល់ដល់ប្រទេសទទួលជំនួយ យើងសង្ឃឹមថាប្រទេសជប៉ុននឹងក្លាយជាអ្នកផ្តួចផ្តើមគំនិតដើម្បីកាត់បន្ថយការព្រួយបារម្ភជាអវិជ្ជមានទាំងនេះ។

ដោយហេតុថា ប្រទេសជប៉ុនក៏មានផ្តល់មូលនិធិទៅតាមរយៈអង្គការអន្តរជាតិនានា ដើម្បីអនុវត្តជំនួយក្នុងវិស័យដែលមានការទាក់ទងជិតគ្នានឹងវិស័យរៀបចំប្រព័ន្ធច្បាប់ដែរនោះ យើងសង្ឃឹមថា លទ្ធផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុននឹងកាន់តែប្រសើរថែមមួយកម្រិតទៀត តាមរយៈការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់ជាទ្វេភាគី ទន្ទឹមគ្នានឹង និងការព្យាយាមសម្រួបសម្រួលជំនួយ ដែលបានផ្តល់មកតាមរយៈមូលនិធិជំនួយជាពហុភាគីនោះ[7]។

---

[6] បច្ចុប្បន្ននេះ ក៏មានសកម្មភាពផ្សព្វផ្សាយនានាត្រូវបានអនុវត្តដែរ ក៏ប៉ុន្តែក្នុងអត្ថបទនេះ យើងចង់ស្នើរឲ្យមានការអនុវត្តដោយសកម្មជាងនេះទៀត។

[7] ការលើកឡើងនេះមិនមែនត្រឹមតែអំពីមូលនិធិជំនួយសម្រាប់ការរៀបចំប្រព័ន្ធច្បាប់តែប៉ុណ្ណោះទេ។ យើងក៏បានគិតទៅដល់មូលនិធិជំនួយ ទាក់ទងនឹងអភិបាលកិច្ចល្អនិងជំនួយចំពោះការកាត់បន្ថយភាពក្រីក្ររបស់UNDP និង ADB ផងដែរ។

### (៦) ការអនុវត្តជំនួយដោយសហការជាមួយស្ថាប័នឯកជនក្នុងដំណាក់កាលជួយពង្រឹងការអនុវត្តច្បាប់

រហូតមកដល់ពេលនេះ ជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន ផ្តោតសំខាន់ទៅលើជំនួយធ្វើការតាក់តែងច្បាប់មូលដ្ឋាននានា និង ការបណ្តុះបណ្តាលធនធានមនុស្សជាដើម ដូចដែលបានអនុវត្តឡើងនៅប្រទេសវៀតណាម និងប្រទេសកម្ពុជា។ យើងគិតថានឹងមានការប្តូរការយកចិត្តទុកដាក់ ចេញពីជំនួយសម្រាប់ដំណាក់កាលពង្រាងច្បាប់ទៅដំណាក់កាលអនុវត្តច្បាប់វិញម្តង។ ដើម្បីឲ្យប្រជាពលរដ្ឋនៃប្រទេសទទួលជំនួយអាចប្រើប្រាស់ច្បាប់នានា រួមទាំងច្បាប់ដែលបានតាក់តែងឡើងក្រោមជំនួយជប៉ុន និង ដើម្បីឲ្យប្រជាពលរដ្ឋអាចទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ ចាំបាច់ត្រូវការបណ្តុះបណ្តាលមេធាវីនៅក្នុងប្រទេសទទួលជំនួយដើម្បីជួយជ្រោមជ្រែង ឲ្យប្រជាពលរដ្ឋអាចប្រើប្រាស់ច្បាប់ទាំងនោះបាន។ ការបញ្ជូនអ្នកជំនាញការជាមេធាវីពីខាងភាគីជប៉ុន ក៏ផ្តល់ផលប្រយោជន៍យ៉ាងច្រើនក្នុងការធ្វើសហប្រតិបត្តិការបច្ចេកទេសសំដៅពង្រឹងមុខងារ របស់មេធាវីនៅប្រទេសទទួលជំនួយផងដែរ។ ប៉ុន្តែ នាពេលបច្ចុប្បន្ននេះ បើសិនជាធ្វើការប្រៀបធៀបរវាងអ្នកជំនាញការដែលជាមេធាវីជាមួយនឹងអ្នកជំនាញការដែលជាចៅក្រម និង ព្រះរាជអាជ្ញាវិញ យើងសង្កេតឃើញថា អ្នកជំនាញការដែលជាមេធាវីមានមូលដ្ឋាននៅខ្សោយ ក្នុងការបំពេញការងារជាអ្នកជំនាញការ។ ឧទាហរណ៍ ការចាត់តាំងធនធានមនុស្សខុសទីកន្លែង កង្វះពេលវេលាត្រៀមខ្លួនឲ្យបានគ្រប់គ្រាន់ កង្វះការគាំទ្របន្ទាប់ពីត្រូវបានបញ្ជូនទៅក្រៅប្រទេសក្នុងអាជីពជាអ្នកជំនាញការភាពមិនអាចធានាបាននូវកម្រៃគ្រប់គ្រាន់ធៀបនឹងពេលមុនត្រូវបានបញ្ជូនទៅធ្វើជាអ្នកជំនាញការ។ បន្ទាប់ពីត្រូវបានបញ្ជូនឲ្យទៅបំពេញការងារជាអ្នកជំនាញការហើយទៀតសោត អ្នកជំនាញការដែលធ្លាប់ជាចៅក្រម និងព្រះរាជអាជ្ញា តែងតែបានទទួលការជួយជ្រោមជ្រែងយ៉ាងសកម្មនូវចំណេះដឹងចាំបាច់ ក្នុងកំឡុងពេលបំពេញការងារជាអ្នកជំនាញការពីសំណាក់ស្ថាប័នទទួលខុសត្រូវដើម (នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្នុងវិទ្យាស្ថានស្រាវជ្រាវទូទៅនៃក្រសួងយុត្តិធម៌ប្រចាំប្រទេសជប៉ុន)។ ចំណែកឯ ការជ្រោមជ្រែងចំពោះអ្នកជំនាញការដែលជាមេធាវីវិញ គេត្រូវពឹងផ្អែកតែលើកិច្ចសហប្រតិបត្តិការជំនួយពីសមាជិកមួយចំនួនរបស់សម្ព័ន្ធគណៈមេធាវីជប៉ុនតាមការស្ម័គ្រចិត្តប៉ុណ្ណោះ។

នាពេលអនាគត យើងគិតថា ការអនុវត្តជំនួយរៀបចំប្រព័ន្ធច្បាប់នឹងត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវចម្បងរបស់ JICA ហើយចាំបាច់ត្រូវកសាងនូវប្រព័ន្ធឧបត្ថមគាំពារក្នុងកំឡុងពេលនៃបេសកកម្មជាអ្នកជំនាញការ ទន្ទឹមនឹងការផ្សាភ្ជាប់កិច្ចសហការឲ្យបានសកម្មជាងមុនជាមួយស្ថាប័នបង្គោលក្រៅរដ្ឋាភិបាល ដែលជំនាញក្នុងវិស័យសេវាកម្មច្បាប់ដូចជា សម្ព័នគណៈមេធាវីជប៉ុនជាដើមដើម្បីសម្រួលដល់ការបញ្ជូន ដូចជាមេធាវី និងអ្នក

ប្រកបវិជ្ជាជីវៈច្បាប់ដទៃទៀតទៅបំពេញការងារជាអ្នកជំនាញការនៅក្រៅប្រទេស។

**(៧) ការផ្សព្វផ្សាយយ៉ាងសកម្មជាសាធារណៈនូវឯកសារដែលទទួលបានពីជំនួយរៀបចំប្រព័ន្ធច្បាប់**

ចំពោះឯកសារនានាដែលបានចងក្រងឡើងដោយ ជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន ក៏បានទទួលការវាយតម្លៃខ្ពស់ពីសំណាក់អ្នកច្បាប់ និងអ្នកចូលរួមសិក្ខាសាលាក្នុងប្រទេសទទួលជំនួយដែរ។ ប៉ុន្តែ បច្ចុប្បន្ន ឯកសារទាំងនោះមិនបានបង្ហាញជាសាធារណៈទាំងអស់នៅលើប្រព័ន្ធអ៊ិនធើណែតនោះទេ។ បើទោះបីជាបានផ្សព្វផ្សាយជាសាធារណៈនៅលើប្រព័ន្ធអ៊ិនធើណែតក៏ដោយ ក៏គេហទំព័រផ្សព្វផ្សាយនោះមិនបានការដឹងឮទូលំទូលាយនៅឡើយដែរ។ ឧទាហរណ៍ ករណីនៅប្រទេសវៀតណាម ការណែនាំអំពីរបៀបសរសេរសាលក្រមនិង ការរៀបចំឯកសារនានា តាមរយៈគម្រោងជំនួយ បានធ្វើឲ្យការអនុវត្តជាក់ស្តែងមានភាពប្រសើរឡើង និង បានទទួលការវាយតម្លៃខ្ពស់ពីសំណាក់ចៅក្រមផងដែរ។ ប៉ុន្តែមានយោបល់របស់អ្នកច្បាប់ខ្លះនៅប្រទេសទទួលជំនួយបានលើកឡើងថា ការផ្សព្វផ្សាយនេះមិនទាន់បានទទួលដឹងឮឲ្យបានទូលំទូលាយនៅឡើយទេ។ ម្យ៉ាងទៀត ស្ថានទូតប្រទេសជប៉ុនប្រចាំប្រទេសនីមួយៗ គួរផ្សព្វផ្សាយឯកសារទាំងអស់នោះជាសាធារណៈតាមទម្រង់នៃការដាក់បណ្តាញលីង នៅក្នុងគេហទំព័ររបស់ខ្លួនដើម្បីអាចទាញយកដោយងាយស្រួល។

ប្រសិនបើ ឯកសារមានប្រយោជន៍ទាំងអស់ដែលបានចងក្រងឡើងក្រោមជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនត្រូវបានផ្សព្វផ្សាយទូលំទូលាយនោះ វានឹងផ្តល់ផលប្រយោជន៍ដល់ការដោះស្រាយបរិមាណ និង គុណភាពនៃការយល់ដឹងរបស់អ្នកច្បាប់នៅប្រទេសកំពុងអភិវឌ្ឍន៍។ ឧទាហរណ៍ ទោះបីជា មេធាវីនៅតាមខេត្តដែលមិនបានចូលរួមសិក្ខាសាលានានាក៏ដោយ ក៏អាចរៀនសូត្របានដូចនៅក្នុងសិក្ខាសាលាដែរ។ នេះប្រហែលជាអាចជួយដល់ការកែលំអរគុណភាពរបស់មេធាវីនៅតាមមូលដ្ឋានបានផងដែរ។ ជាលទ្ធផលយើងនឹងអាចបង្កើនប្រសិទ្ធិផលរបស់ជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុនបាន។

២.៣. អនុសាសន៍ជារួមចំពោះភាគីពាក់ព័ន្ធទាំងអស់ក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់ជប៉ុន

បន្ថែមទៅលើ អនុសាសន៍ខាងលើដែលបានតម្រង់ទៅកាន់ ក្រសួងការបរទេស និង JICA នៅក្នុងផ្នែកនេះ យើងសូមផ្តល់អនុសាសន៍រួមចំពោះភាគីពាក់ព័ន្ធទាំងអស់ក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនវិញម្តង។ ភាគីពាក់ព័ន្ធក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់មិនមែនមានតែ ក្រសួងការបរទេស និង JICA ប៉ុណ្ណោះទេ រួមទាំងភាគីជាច្រើនផ្សេងទៀតដូចជា ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច ក្រសួងហិរញ្ញវត្ថុ ក្រសួងអប់រំ និង ក្រសួងឬនាយកដ្ឋាននានានៃប្រទេសជប៉ុន ព្រមទាំងមជ្ឈដ្ឋានអង្គការពាណិកម្ម សាកលវិទ្យាល័យ គណៈមេធាវីជប៉ុន និង NGO។ ជាពិសេស យើងសូមផ្តល់អនុសាសន៍ដូចតទៅជូន ចំពោះភាគីពាក់ព័ន្ធទាំងអស់ក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ដើម្បីឲ្យប្រសិទ្ធិផលនៃជំនួយរៀបចំប្រព័ន្ធច្បាប់កើនឡើងថែមមួយកំរិតទៀត សម្រាប់រយៈពេលកណ្តាល និងរយៈពេលវែងខាងមុខ។ យើងសង្ឃឹមយ៉ាងមុតមាំថា ក្រសួងការបរទេស និង JICA ដែលជាភ្នាក់ងារកណ្តាលក្នុងការទទួលខុសត្រូវចំពោះកិច្ចការរបស់ ODA នឹងប្រើប្រាស់សិទ្ធិអំណាច ព្រមទាំងទំនួលខុសត្រូវរបស់ខ្លួនពាំនាំអនុសាសន៍ទាំងអស់នេះទៅជូនភាគីដែលពាក់ព័ន្ធ ហើយនឹងព្យាយាមប្រឹងប្រែងចាត់វិធានការណ៍ជាក់ស្តែងសម្រាប់អនុវត្តតាមទិសដៅនៃអនុសាសន៍ទាំងនេះបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធរួចមក។

### (១)ការពង្រីកប្រព័ន្ធជំនួយដោយចាប់អារម្មណ៍លើការផ្តល់ផលប្រយោជន៍ដល់សហគ្រាសជប៉ុន

នៅក្នុងសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ស្តីអំពីគោលការណ៍ជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នាខែកុម្ភៈឆ្នាំ២០១៥ បានបញ្ជាក់ច្បាស់លាស់ជាងមុននូវឥរិយាបទផ្តោតសំខាន់ទៅលើផលប្រយោជន៍ជាតិ។ ក្នុងន័យនេះ យើងគួរត្រួតពិនិត្យឲ្យបានហ្មត់ចត់ និង សម្លឹងមើលឲ្យបានវែងឆ្ងាយអំពីអត្ថន័យនៃពាក្យថាផលប្រយោជន៍ជាតិ នៅក្នុងបរិបទនៃជំនួយរៀបចំប្រព័ន្ធច្បាប់ដែលបានប្រព្រឹត្តតាំងពីដំបូងមក។ ជាពិសេស ចំពោះទស្សនៈទានស្តីពីផលប្រយោជន៍របស់សហគ្រាសជប៉ុន យើងចាំបាច់ផ្តល់ជំនួយក្នុងការរៀបចំប្រព័ន្ធច្បាប់សម្រួលឲ្យការវិនិយោគរយៈពេលវែង ក្នុងបរិយាកាសល្អដោយមានការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច ក្រសួងនិងនាយកដ្ឋានហិរញ្ញវត្ថុ ព្រមទាំងស្ថាប័ន និង អង្គការសេដ្ឋកិច្ចនានា។ យើងរំពឹងថា នឹងរួមចំណែកចូលរួមផ្តល់ផ្តល់ផលប្រយោជន៍ដល់ជាតិសម្រាប់រយៈពេលកណ្តាល និងរយៈពេលវែង តាមរយៈការផ្តល់នូវជំនឿចិត្តចំពោះប្រទេសជប៉ុន ដោយគាំទ្រសកម្មភាពរបស់សហគ្រាសជប៉ុនដែលបានគោរពនូវគោលការណ៍ទាំង១០ ក្នុងក្របខ័ណ្ឌនៃការព្រម

ព្រៀងជាសកល[8] នៃអង្គការសហប្រជាជាតិ (UN Global Compact) រួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុលរលួយ លើកស្ទួយវិស័យការងារ វិស័យបរិស្ថាន និងវិស័យសិទ្ធិមនុស្ស នៅប្រទេសទទួលជំនួយ។ កិច្ចគាំទ្រនេះនឹងជួយលើកតម្កើងរូបភាពស្អាតស្អំនៃសហគ្រាសជប៉ុន និង សម្រួលឲ្យមានការលេចឡើងនូវយីហោថ្មីៗទៀតដែលគេអាចជឿទុកចិត្តបានលើឆាកអន្តរជាតិ។

ជំនួយរៀបចំប្រព័ន្ធច្បាប់ ប្រព្រឹត្តិទៅដោយមានការបញ្ជូនអ្នកច្បាប់ពីប្រទេសជប៉ុន និងជម្រុញឲ្យអ្នកច្បាប់ទាំងនោះស្វែងយល់អំពីប្រព័ន្ធច្បាប់របស់ប្រទេសទទួលជំនួយ តាមរយៈកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស។ គំនិត និង ចំណេះដឹងដែលអ្នកច្បាប់ជប៉ុនទទួលបានតាមរយៈគម្រោងសហប្រតិបត្តិការផ្នែកបច្ចេកទេសនេះ ពិតជាមានសារៈប្រយោជន៍យ៉ាងខ្លាំងចំពោះសហគ្រាសជប៉ុនដែលមានទីតាំងនៅប្រទេសទទួលជំនួយ។ ឧទាហរណ៍ ក្នុងករណីដែលមានការកែប្រែច្បាប់ទាក់ទងនឹងសកម្មភាពរបស់សហគ្រាសនៅក្នុងប្រទេសទទួលជំនួយ ដូចជាក្រមពាណិជ្ជកម្មជាដើម អ្នកជំនាញការអាចរៀបចំសិក្ខាសាលាបង្ហាញអំពីចំណុចនៃការកែប្រែទាំងអស់នោះ ជូនចំពោះសហគ្រាសជប៉ុននៅនឹងន្លែងក្រោយពេលបញ្ចប់អាណត្តិរបស់ខ្លួន[9]។

ម្យ៉ាងវិញទៀត ប្រសិនបើមេធាវីជប៉ុនអាចក្តាប់បាននូវតម្រូវការនៃសេវាកម្មច្បាប់នានាសម្រាប់សហគ្រាសជប៉ុនដែលដំណើរការនៅប្រទេសទទួលជំនួយបាននោះ ការិយាល័យមេធាវីនៅប្រទេសជប៉ុនក៏អាចមើលឃើញឱកាសពង្រីកធុរកិច្ចរបស់ខ្លួន ក្នុងវិស័យច្បាប់បានក្រោយពេលបញ្ចប់ជំនួយរៀបចំប្រព័ន្ធច្បាប់រួចរាល់ហើយនោះ។ ពួកគាត់នឹងអាចបញ្ជូនធនធានមនុស្សរបស់ខ្លួន ចូលរួមជាយុទ្ធសាស្ត្រក្នុងការងារផ្តល់ជំនួយរៀបចំប្រព័ន្ធច្បាប់នេះដែរ។ ជាលទ្ធផល ជំនួយរៀបចំប្រព័ន្ធច្បាប់នឹងក្លាយទៅជាចលនាមួយដែលអាចវិលមកបំរើផលប្រយោជន៍ប្រទេសជប៉ុនវិញបាន។ ដោយសារ យើងមានឱកាសពង្រឹងសមត្ថភាពមេធាវីជប៉ុន ហើយ មេធាវីដែលត្រូវបានបណ្តុះបណ្តាលទាំងនោះនឹងមានសមត្ថភាពជួយជ្រោមជ្រែងសហគ្រាសជប៉ុន ចំណែកឯ សហគ្រាសជប៉ុនវិញក៏មានសមត្ថភាពអាចធ្វើសកម្មភាពសេដ្ឋកិច្ចដោយសេរីនិងត្រឹមត្រូវបានដែរ។

[8] គោលការណ៍ទាំង១០នោះ តម្រូវឲ្យសហគ្រាស និងនីតិបុគ្គលនានា ដឹកនាំអាជីវកម្មរបស់ខ្លួនដោយមានការទទួលខុសត្រូវ និងថ្មៃប្រឌិត ហើយប្រកបជាសមាជិកល្អមួយក្នុងសង្គម។ សកម្មភាពសហគ្រាស និងនីតិបុគ្គលទាំងនោះអាចចូលរួមដោយស្ម័គ្រចិត្តក្នុងបណ្តាញសហប្រតិបត្តិការជាអន្តរជាតិ ដើម្បីរួមចំណែកសម្រេចឲ្យបាននូវការរីកចម្រើនដោយចេរភាព ដោយការការពារសិទ្ធិមនុស្ស លុបបំបាត់រាល់អំពើកេងប្រវ័ញ្ចពលកម្ម ព្រមទាំង គិតគូរដល់បរិស្ថាន ទប់ស្កាត់អំពើពុករលួយ។ (សូមស្រាវជ្រាវតាមរយៈគេហទំព័រ Global-Compact-Japan-Network)

[9] ការរក្សានូវតវិយាបថអព្យាក្រឹត្យនៅក្នុងជំនួយរៀបចំប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុន កំពុងទទួលបានការវាយតម្លៃល្អពីសំណាក់ប្រទេសទទួលជំនួយ ដូច្នេះយើងចាំបាច់ត្រូវបន្តរក្សាអព្យាក្រឹតភាពនេះ ទន្ទឹមនឹងការគិតគូរដល់ប្រយោជន៍ជាតិ។

បន្ថែមពីលើនេះទៅទៀត មានការិយាល័យមេធាវីជប៉ុនខ្លះបានដំណើរការរួចហើយនៅតាមបណ្តាប្រទេសទទួលជំនួយ។ ក្នុងករណីនេះ គួរពង្រឹងសាមគ្គីភាពរវាងមេធាវីទាំងនោះ និងបង្កើតប្រព័ន្ធសហការជាមួយនឹងមេធាវីដែលក្តាប់បាននូវតម្រូវការរបស់សហគ្រាសជប៉ុននៅប្រទេសទទួលជំនួយ ព្រមទាំងប្រព័ន្ធច្បាប់នៃប្រទេសទទួលជំនួយ។ លើសពីនេះទៅទៀត ការចែករំលែកនូវចំណេះដឹងទាំងអស់នេះចំពោះគ្នាទៅវិញទៅមក ក៏នឹងក្លាយជាផលប្រយោជន៍ចំពោះប្រទេសជប៉ុនទាំងមូលផងដែរ។

ជាពិសេស ស្ថានទូតជប៉ុនប្រចាំប្រទេសទាំងនោះ គួរសម្រួលឲ្យមាននូវបរិយាកាសល្អកើតឡើងដូចបានរៀបរាប់ខាងលើ ដោយពឹងពាក់ការិយាល័យមេធាវីជប៉ុនដែលមានទីតាំងនៅប្រទេសទទួលជំនួយ ឲ្យផ្តល់ជាសេវាកម្មប្រឹក្សាច្បាប់ទៅកាន់បុគ្គល ឬ ស្ថាប័នជប៉ុននៅនឹងកន្លែង ឬតែងតាំងមេធាវីជាមន្ត្រីរាជការប្រចាំស្ថានទូតផ្ទាល់ មានឋានៈសមរម្យសម្រាប់បម្រើការងារក្នុងរយៈពេលកំណត់ ដើម្បីទទួលបន្ទុកទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់។ មន្ត្រីថ្មីនេះមានតួនាទីប្រមូលព័ត៌មានដែលទាក់ទងនឹងការអនុវត្តប្រព័ន្ធច្បាប់ពី NGO សហគ្រាសជប៉ុននានា និងផ្តល់ការពិគ្រោះយោបល់ទាក់ទងនឹងករណីជាក់ស្តែង។ ក្នុងឱកាសនេះ ចំពោះបណ្តាប្រទេសដែលមានសហគ្រាសជប៉ុនកំពុងប្រកបអាជីវកម្មយ៉ាងខ្លាំងក្លា (ពិសេសប្រទេសដែលបានចុះកិច្ចព្រៀមព្រៀងជាដៃគូសេដ្ឋកិច្ច EPA ជាមួយប្រទេសជប៉ុន)ក៏គួរតែជម្រុញឲ្យមានកិច្ចសហការផ្តល់ជាជំនួយរៀបចំប្រព័ន្ធច្បាប់ ដើម្បីសម្រួលឲ្យមានបរិយាកាសវិនិយោគល្អ ដោយបង្កើតនូវប្រព័ន្ធដោះស្រាយវិវាទក្រៅតុលាការ (ADR) រវាងប្រទេសទាំងពីរ (ការផ្សះផ្សា មជ្ឈិតកម្មដឹកនាំដោយ មេធាវីប្រទេសជប៉ុន មេធាវីនៃប្រទេសសាមី និងអ្នកឯកទេសមកពីប្រទេសទី៣) ដែលអាចដោះស្រាយយ៉ាងមានយុត្តិធម៌ និងឆាប់រហ័សនូវវិវាទរដ្ឋប្បវេណី ឬ វិវាទពាណិជ្ជកម្ម ជាក់ស្តែងទាក់ទងនិងសហគ្រាសជប៉ុននៅនឹងកន្លែងដោយប្រើច្បាប់របស់ប្រទេសជាដៃគូនោះ។ កិច្ចសហការបែបនេះអាចនាំឲ្យតុលាការនៃប្រទេសជាដៃគូ ទទួលបាននូវសេចក្តីទុកចិត្តពីសំណាក់សហគ្រាសជប៉ុននានានៅពេលអនាគតផងដែរ។

### (២) ការបណ្តុះបណ្តាលអ្នកជំនាញការក្នុងវិស័យជំនួយច្បាប់

ដូចដែលបានរៀបរាប់នៅក្នុងចំណុច ៥.៣.៤ ជំនួយរៀបចំប្រព័ន្ធច្បាប់នៃប្រទេសជប៉ុនបានទទួលការវាយតម្លៃខ្ពស់ ដោយសារតែមានអ្នកជំនាញការដែលបានបញ្ជូនតាមរយៈJICA សម្ព័ន្ធគណៈមេធាវីជប៉ុន ក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ព្រមទាំងក្រុមអ្នកមានចំណេះវិជ្ជាខ្ពស់ជាសមាជិកនៃគណៈកម្មការជំនាញនានានៅក្នុងប្រទេសជប៉ុន បានខិតខំសម្រេចឲ្យបាននូវជំនួយដែលមានជំនាញខ្ពស់ទៅកាន់ប្រទេសទទួលជំនួយ។ លក្ខណៈនៃជំនួយដែលអនុវត្តដោយក្រុមអ្នកមានជំនាញខ្ពស់បែបនេះ មិនត្រឹមតែទទួលបានការវាយតម្លៃខ្ពស់ពីសំណាក់ប្រទេសទទួលជំនួយផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវការវាយតម្លៃខ្ពស់ពីម្ចាស់ជំនួយផ្សេងៗទៀតផងដែរ។ ប៉ុន្តែ ដូចមានរៀបរាប់នៅក្នុងចំណុចដំបូងនៃអនុសាសន៍ជំនួយរៀបចំ

ប្រព័ន្ធច្បាប់បានឈានចូលដល់ដំណាក់កាលជម្រុញនីតិរដ្ឋ ដោយផ្អែកលើការអនុវត្តឲ្យបានត្រឹមត្រូវនូវច្បាប់ដែលបានរៀបចំឡើងហើយនោះ និង តាមរយៈប្រព័ន្ធតុលាការដែលប្រកបទៅដោយឯករាជ្យភាព និងតល្លាភាព។ ដើម្បីសម្រេចឲ្យបាននូវលទ្ធផលទាំងនេះ យើងត្រូវយល់ដឹងអំពីស្ថានភាពពិតនៃការប្រើប្រាស់សិទ្ធិរបស់បុគ្គលម្នាក់ៗ ពិនិត្យមើលប្រសិទ្ធិផលនៃជំនួយនៅថ្នាក់មូលដ្ឋាន ហើយនិងទទួលមតិយោបល់តបចំពោះបញ្ហាដែលបានសង្កេតឃើញ ដើម្បីអនុវត្តជំនួយចាំបាច់ទាំងឡាយឲ្យស្របតាមតម្រូវការនៃស្ថានភាពជាក់ស្តែង។

ដោយសារតែ ជំនួយក្នុងពេលកន្លងមកត្រូវពឹងពាក់ទាំងស្រុងលើបុគ្គលជាអ្នកជំនាញការមានជំនាញការងារច្បាប់ បទពិសោធន៍ ការប្តេជ្ញាចិត្ត និង បណ្តាញជ្រោមជ្រែងការងាររៀងៗខ្លួននោះ មានការព្រួយបារម្ភថាតើ ជំនួយបែបនេះអាចឆ្លើយតបបានគ្រប់គ្រាន់ចំពោះទាំងគុណភាព និងបរិមាណនៃតម្រូវការជំនួយដែលមានការប្រែប្រួលជារឿយៗនោះដែរឬទេ។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃជំនួយរៀបចំប្រព័ន្ធច្បាប់បាន ហើយនឹងដើម្បីឆ្លើយតបទៅនឹងទិសដៅរយៈពេលវែងនៃជំនួយរៀបចំប្រព័ន្ធច្បាប់ដែលសំដៅលើកស្ទួយការយល់ដឹងអំពីច្បាប់ និង ស្មារតីគោរពច្បាប់របស់មនុស្សគ្រប់ៗគ្នានោះ នៅក្នុងប្រទេសជប៉ុនក៏ត្រូវតែមានការបណ្តុះបណ្តាលធនធានមនុស្សតាមជំនាញផ្សេងៗ ដែលទទួលបន្ទុកការងារជំនួយរៀបចំប្រព័ន្ធច្បាប់ជាលក្ខណៈអចិន្ត្រៃយ៍ផងដែរ។ ដូចនេះ ស្ថាប័នពាក់ព័ន្ធនីមួយៗត្រូវទទួលបន្ទុកក្នុងការបំពេញតួនាទីតាមអ្វីដែលបានរំពឹងទុកជាមុន ដើម្បីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់រៀងខ្លួន។ ឧទាហរណ៍ ដើម្បីបំពេញតម្រូវការស្រាវជ្រាវនានាបាន ចាំបាច់ត្រូវតែមានកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ ជាពិសេស ត្រូវមានកិច្ចសហការពីសំណាក់អ្នកជំនាញសិក្សាស្រាវជ្រាវអំពីតំបន់នានា អំពីច្បាប់នៅអាស៊ី និងអំពីនីតិសង្គមវិជ្ជាជាដើម។ ម៉្យាងទៀតការបណ្តុះបណ្តាលធនធានមនុស្សពីចំណេះដឹងទាក់ទងនឹងនីតិរដ្ឋអាចសម្រេចបាន តាមរយៈការបញ្ចូលកម្មវិធីសិក្សាអំពីជំនួយរៀបចំប្រព័ន្ធច្បាប់ ទៅក្នុងមុខវិជ្ជាសិក្សានៃសាលាវិជ្ជាជីវៈច្បាប់ថ្នាក់ក្រោយឧត្តមនៅក្នុងប្រទេសជប៉ុន(Law School) ហើយសម្រួលឲ្យនិស្សិតអាចជ្រើសរើសសិក្សាមុខវិជ្ជានេះ និង ត្រូវបញ្ជូនសិស្សឲ្យទៅធ្វើកម្មសិក្សានៅប្រទេសកំពុងអភិវឌ្ឍន៍ដែលបានទទួលជំនួយរៀបចំប្រព័ន្ធច្បាប់តាមរយៈកម្មវិធីគ្លីនិកច្បាប់(Legal Clinic) ជាអាទិ៍។

បន្ថែមពីនេះទៀត វាក៏មានប្រយោជន៍ផងដែរ ក្នុងការបញ្ចូលកម្មវិធីចុះកម្មសិក្សាទាក់ទងនឹងជំនួយរៀបចំប្រព័ន្ធច្បាប់ សម្រាប់អប់រំអ្នកដែលទទួលបានលក្ខណៈសម្បត្តិជាសិស្សចៅក្រម ព្រះរាជអាជ្ញានិងមេធាវី និង សម្រាប់អនុវត្តនៅឯមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈច្បាប់ក្រោមឱវាទរបស់តុលាការកំពូល។ ជាងនេះទៅទៀត JICA និង ក្រសួងការបរទេស មិនត្រឹមតែសហការជាមួយតុលាការ ក្រសួងយុត្តិធម៌ និង គណៈមេធាវីប៉ុណ្ណោះទេ ថែមទាំងត្រូវពង្រីកកិច្ចសហការជាមួយក្រសួងអប់រំ និង ក្រសួងឧស្សាហកម្មនិងសេដ្ឋកិច្ច ព្រមទាំងក្រសួងស្ថាប័នផ្សេងទៀតរបស់ប្រទេសជប៉ុន ដើម្បីអញ្ជើញនិស្សិតច្បាប់ អ្នកកំពុងធ្វើកម្មសិក្សាវិជ្ជាជីវៈ

ច្បាប់ និងអ្នកអនុវត្តច្បាប់មកពីប្រទេសកំពុងអភិវឌ្ឍន៍ឲ្យមកសិក្សានៅជប៉ុនក្នុងនាមជានិស្សិត។ លើសពីនេះ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់និស្សិតជប៉ុន អ្នកច្បាប់ជប៉ុននិងសហគ្រិនជប៉ុនឲ្យបានស៊ីជម្រៅទាក់ទងនឹងប្រព័ន្ធច្បាប់នៃប្រទេសកំពុងអភិវឌ្ឍន៍ យើងគួរប្រើប្រាស់នូវកម្មវិធីផ្សព្វផ្សាយ ស្រាវជ្រាវ ចុះត្រួតពិនិត្យ អប់រំកម្មសិក្សានានា របស់អង្គការ UNAFEI និងអង្គការJETRO ជាដើម។ បន្ថែមពីនេះ ការបញ្ជូនអ្នកអនុវត្តច្បាប់ពីប្រទេសជប៉ុនទៅចូលរួមក្នុងកម្មវិធីសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍ដែលរៀបចំឡើងដោយ JICA (South-South Cooperation) ក៏អាចចាត់ទុកបានថាជាមធ្យោបាយមួយសម្រាប់ជម្រុញការយល់ដឹងអំពីការអនុវត្តច្បាប់នៅប្រទេសកំពុងអភិវឌ្ឍន៍ដែរ។

ចំណែកឯនៅក្នុងសាកលវិទ្យាល័យ ត្រូវមានទំនាក់ទំនងជាមួយនឹងក្រុមជំនុំសិក្សាស្រាវជ្រាវទាក់ទងនឹងវិស័យផ្សេងៗ (Academic Society) (កិច្ចប្រជុំសិក្សាច្បាប់អាស៊ី កិច្ចប្រជុំអាស៊ីសម្រាប់សិក្សាច្បាប់អន្តរជាតិ កិច្ចប្រជុំសិក្សានីតិសង្គមវិជ្ជា កិច្ចប្រជុំសិក្សានីតិប្រៀបធៀប កិច្ចប្រជុំសិក្សាវិជ្ជាអភិវឌ្ឍន៍អន្តរជាតិជាដើម) ព្រមទាំងក្រុមស្រាវជ្រាវនៅតាមប្រទេសផ្សេងៗ (Study Group) (ជម្រុញឲ្យមានការផ្តួចផ្តើមគំនិតនៅក្នុងប្រទេសទទួលជំនួយរៀបចំកិច្ចប្រជុំស្រាវជ្រាវនីតិប្រៀបធៀប ដូចនៅក្នុងប្រទេសកម្ពុជាជាដើម)ដើម្បីពង្រឹងការយល់ដឹងអំពីប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗ។ ក្រៅពីនេះ ការរៀបចំសម្រួលឲ្យមានការបញ្ជូនអ្នកច្បាប់ពីក្រសួងនានា និង គណៈមេធាវី ទៅកាន់ស្ថាប័នអន្តរជាតិ (ដូចជា ធនាគារពិភពលោក UNDP ជាអាទិ៍) ក៏មានភាពចាំបាច់ផងដែរ។ វាជម្រុញទំនាក់ទំនងក្នុងការអនុវត្តជាក់ស្តែង តាមរយៈការបង្កើតបណ្តាញទំនាក់ទំនងរវាងអ្នកជំនាញការ ដែលធ្លាប់ធ្វើការជាមួយគ្នានៅការិយាល័យកណ្តាល ឬតាមរយៈកម្មសិក្សារួមគ្នានៅក្នុងការិយាល័យថ្នាក់មូលដ្ឋាននៃស្ថាប័នអន្តរជាតិទាំងនោះ។

ការបណ្តុះបណ្តាលធនធានមនុស្សចំរុះបែប ដើម្បីទទួលបន្ទុកជំនួយរៀបចំប្រព័ន្ធច្បាប់ទាំងក្នុងប្រទេសនិងជាសកលឲ្យបានគ្រប់ជ្រុងជ្រោយ នឹងធ្វើឲ្យមានការយល់គ្នាទៅវិញទៅមករវាងប្រទេសជប៉ុននិងប្រទេសទទួលជំនួយ និងជម្រុញដល់ការអប់រំរៀនសូត្រពីគ្នាទៅវិញទៅមករវាងអ្នកទទួលខុសត្រូវកសាងនីតិរដ្ឋក្នុងប្រទេសទាំងពីរ ព្រមទាំងចូលរួមចំណែកពង្រីក និងពង្រឹងអំណាចទន់របស់ប្រទេសជប៉ុន។ ពោលគឺ ការបណ្តុះបណ្តាលធនធានមនុស្សយ៉ាងទូលំទូលាយសម្រាប់វិស័យជំនួយរៀបចំប្រព័ន្ធច្បាប់នឹងនាំមកនូវផលប្រយោជន៍ជូនសហគ្រាសជប៉ុនផង ហើយក៏ជំរុញឲ្យមានការរៀបចំឡើងនូវទីផ្សារដែលមានស្ថេរភាព និងដំណើរការត្រឹមត្រូវដើម្បីសម្រេចបាននូវនីតិរដ្ឋនិងការធានាសន្តិសុខមនុស្សជាតិផង។ ការបណ្តុះបណ្តាលនេះថែមទាំងមានសារៈសំខាន់ជាទីបំផុតក្នុងការសម្រេចបាននូវនយោបាយការទូតទូលំទូលាយ ប្រកបដោយទិដ្ឋភាពច្រើនយ៉ាងដែលមានការចូលរួមរបស់រដ្ឋាភិបាលប្រជាពលរដ្ឋនិងផ្នែកឧស្សាហកម្មផងដែរ។